ធនាគារជាតិនៃកម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ត្រួតពិនិត្យ
# ប្រចាំឆ្នាំ ២០១៨

អគ្គនាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១៨នេះ ត្រូវបានព្យាករថានឹងកើនឡើង ៣,៦% ប្រហាក់ប្រហែលនឹងឆ្នាំមុន។ ដោយឡែក សេដ្ឋកិច្ចតំបន់អាស៊ីក៏បានបង្ហាញនូវសក្តានុពល និងរក្សានូវកំណើនសេដ្ឋកិច្ចរបស់ខ្លួនល្អប្រសើរ ដោយត្រូវបានរំពឹងទុកថានឹងមានកំណើនប្រមាណ ៥,៥%។ កំណើនសេដ្ឋកិច្ចនេះ បានផ្តល់កាលានុវត្តភាពល្អដល់សេដ្ឋកិច្ចកម្ពុជា ពិសេស ចំពោះការនាំចេញ ទេសចរណ៍ និងសំណង់ គឺជាកម្លាំងចលករយ៉ាងសំខាន់គាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជាឲ្យសម្រេចបាន ៧,៥% នៅឆ្នាំ២០១៨។ ការបន្តហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស កំណើននៃតម្រូវការក្នុងស្រុក ភាពលូតលាស់នៃសកម្មភាពអាជីវកម្ម គួបផ្សំនឹងភាពល្អប្រសើរនៃពាណិជ្ជកម្មអន្តរជាតិ ជាកត្តាលីករបន្តរក្សាចលនាកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលមធ្យម។ ស្ថិរភាពនយោបាយ និងសុខសន្តិភាពទូទាំងប្រទេសក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់ផលវិជ្ជមានក្នុងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងការលើកកម្ពស់កម្រិតជីវភាពប្រជាជនឲ្យកាន់តែមានភាពប្រសើរឡើង តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការបង្កើនការវិនិយោគក្នុងស្រុក ការបង្កើតការងារជូនប្រជាពលរដ្ឋ ការធានាសមធម៌សង្គម និងការពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ។ កត្តាទាំងអស់នេះ បានជំរុញសមាហរណកម្ម សេដ្ឋកិច្ចកម្ពុជាយ៉ាងសកម្មទៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់និងពិភពលោក។ វិស័យធនាគារបាននិងកំពុងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយតុល្យភាព និងបរិយាប័ន្ន។

ភាពអំណោយផលនៃស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ធ្វើឲ្យវិស័យធនាគារបន្តរីកចម្រើនគួរឲ្យកត់សម្គាល់។ ប្រព័ន្ធធនាគារបានបង្ហាញឲ្យឃើញពីភាពរឹងមាំដែលអាចធន់នឹងបរិយាកាសប្រកួតប្រជែងទាំងក្នុងស្រុកនិងអន្តរជាតិ ការបង្កើននូវជំនឿទុកចិត្តរយៈពេលវែងរបស់ប្រជាជន និងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពនិងទូលំទូលាយជាងមុន។ ទន្ទឹមនឹងការរីកចម្រើននៃវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបាននិងបន្តការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងសុខុមាលភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារ។ បទប្បញ្ញត្តិនៃការត្រួតពិនិត្យជាច្រើនត្រូវបានដាក់ចេញឲ្យអនុវត្តជាបន្តបន្ទាប់ ជាពិសេស វិធានការម៉ាក្រូប្រុងប្រយ័ត្ន រួមមាន ការបង្កើនដើមទុន ការពង្រឹងអនុបាតក្របខណ្ឌសន្ទនីយភាព យន្តការគ្រប់គ្រងហានិភ័យសន្ទនីយភាព ការពង្រឹងគុណភាពទ្រព្យសកម្មការកំណត់ទ្រនាប់ដើមទុនតាមគោលការណ៍គ្រឹះបាសែល សំដៅបង្កើនភាពធន់នឹងវិបត្តិឲ្យបានល្អប្រសើរ និងទប់ស្កាត់ហានិភ័យជាប្រព័ន្ធ។ ជាមួយគ្នានេះ ឈរលើមូលដ្ឋានឧត្តមានុវត្តភាពអន្តរជាតិ ប្រកាសមួយចំនួនទៀតដូចជា ការគណនាអនុបាតសាធនភាព និងការឆ្លើយតបផ្នែកត្រួតពិនិត្យទៅលើធនាគារដែលទន់ខ្សោយ កំពុងស្ថិតក្នុងដំណាក់កាលកែសម្រួល និងរៀបចំដាក់ឲ្យអនុវត្តនៅជំហានបន្ទាប់ដោយផ្អែកតាមមូលដ្ឋានច្បាប់ ហានិភ័យ និងទស្សនៈអនាគត។

ចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសមាហរណកម្មក្នុងតំបន់ ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់លើការអនុវត្តស្តង់ដារគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុឲ្យមានសង្គតិភាព និងបន្តធ្វើបច្ចុប្បន្នកម្មប្លង់គណនីឯកភាព ដើម្បីឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត។ ការរីកចម្រើនខ្លាំងទាំងផ្នែកសេវានិងមធ្យោបាយទូទាត់សងប្រាក់ ក៏ទាមទារឲ្យមានយន្តការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាដើម្បីការពារសុវត្ថិភាពអតិថិជននិងប្រព័ន្ធធនាគារទាំងមូល។ ព័ត៌មានស្តីពីឥណទានក្រុមហ៊ុនក៏ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) បន្ថែមលើឥណទានឯកត្តបុគ្គលដែលមានស្រាប់ ជាជំនួយដល់ការវិភាគគុណភាពឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ គំនិតផ្តួចផ្តើមគម្រោងថ្មីៗក្នុងន័យលើកកម្ពស់ការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដល់ស្ត្រីត្រូវបានដាក់ចេញឲ្យស្របតាមយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ។ លើសពីនេះធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅ និងសេវាផ្តល់ដំបូន្មានផ្នែកហិរញ្ញវត្ថុជាសំឡេង ៣-២-១ ហើយកិច្ចការពារអតិថិជនត្រូវបានពង្រឹងបន្ថែម ក្នុងនោះរួមមានការបង្កើតក្រុមការងារគាំពារអតិថិជន ប្រព័ន្ធទូរស័ព្ទទំនាក់ទំនង (Hotline) អំពីចម្ងល់និងបញ្ហាពាក់ព័ន្ធការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងសេចក្តីជូនដំណឹងអំពីសកម្មភាពផ្តល់កម្ចីខុសច្បាប់ក៏ដូចជាការប្រើប្រាស់កាសអេឡិចត្រូនិក។ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាសមាជិកនៅក្នុងសមាគមធានារ៉ាប់រងប្រាក់បញ្ញើអន្តរជាតិ (IADI) អាចទទួលបានការបណ្តុះ-បណ្តាលនិងបទពិសោធន៍ សម្រាប់ជាធាតុចូលបន្ថែមចំពោះការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើពីស្ថាប័នជាសមាជិក លើការកំណត់អត្រាបុព្វលាភ និងក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ។ ក្នុងទិសដៅបន្តនូវប្រសិទ្ធភាពការងារ ពិសេសការដាក់ចេញនូវវិធានការសមស្របនិងទាន់ពេលវេលា ការពង្រឹងគុណវុឌ្ឍិមន្ត្រីត្រួតពិនិត្យត្រូវបានធ្វើឡើងជាប់ជាប្រចាំ ទាំងផ្នែកចំណេះដឹងនិងជំនាញទន់ (soft skills) ក៏ដូចជាការផ្សារភ្ជាប់ផ្នែកទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង តាមរយៈក្របខណ្ឌកិច្ចសហ-ប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស។

ធនាគារជាតិនៃកម្ពុជានឹងបន្តចូលរួមចំណែកគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋា-ភិបាល និងបន្តពង្រឹងជំនឿទុកចិត្តនិងអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ភាពរឹងមាំ ភាពប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងបន្តរក្សាឲ្យបានស្ថិរភាពថ្លៃ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥។ ធនាគារជាតិនៃកម្ពុជានឹងបន្តលើកកម្ពស់ការត្រួតពិនិត្យកិច្ចគាំពារអតិថិជន ការប្រើប្រាស់រូបិយវត្ថុជាតិ និងបរិយាប័ន្នហិរញ្ញវត្ថុ ដែលជាការប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយ និងមានតម្លៃសមរម្យសម្រាប់ប្រជាជន។

ថ្ងៃចន្ទ ១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

**ជា ចាន់តូ**

**ទេសាភិបាល**

**ធនាគារជាតិនៃកម្ពុជា**

# មាតិកា

**អារម្ភកថា** ........ i
**បញ្ជីរូបភាពនិងតារាង** ........ v
**១. ការអភិវឌ្ឍសំខាន់ៗនៃប្រព័ន្ធធនាគារ** ........ ១
១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១
១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ........ ៤
១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ ........ ៤
១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ ........ ៨
១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ ........ ១១
១.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ ........ ១២
១.២.៥. ប្រតិបត្តិការនៃអាជីវកម្មប្តូរប្រាក់ ........ ១២
**២. ការវិវឌ្ឍក្របខណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ** ........ ១៣
២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ ........ ១៣
២.១.១. ការដាក់ឲ្យអនុវត្តនូវទម្រង់របាយការណ៍អត្រាការប្រាក់មធ្យមថ្លឹង ចំពោះប្រាក់បញ្ញើនិងឥណទាន ........ ១៦
២.១.២. ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន ........ ១៦
២.១.៣. ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១៧
២.១.៤. ការអនុវត្តប្រកាសស្តីពីកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១៨
២.១.៥. ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ........ ១៨
២.២. សកម្មភាពនៃការត្រួតពិនិត្យ ........ ១៨
២.៣. ការបញ្ចប់ប្រតិបត្តិការរបស់គ្រឹះស្ថានប្រតិស្រុតិ ........ ១៩
**៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់** ........ ១៩
៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ........ ១៩
៣.១.១. ស្តង់ដារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ........ ១៩
៣.១.២. ការិយាល័យព័ត៌មានឥណទានកម្ពុជា ........ ២០
៣.១.៣. ប្រតិបត្តិការប្រព័ន្ធទូទាត់ ........ ២១
៣.២. ការអនុវត្តការងារបរិយាប័ន្នហិរញ្ញវត្ថុ ........ ២៣
៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ........ ២៥
៣.៤. ប្រតិបត្តិការទីផ្សារអន្តរធនាគារ ........ ២៧

៣.៥. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ........................................................ ២៨
៣.៦. យន្តការការពារអ្នកដាក់ប្រាក់បញ្ញើ ........................................................ ៣០
**៤. ការកសាងសមត្ថភាពត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ** ........................ ៣១
៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ........................................................ ៣១
៤.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................................ ៣១
**បញ្ជីឧបសម្ព័ន្ធ** ........................................................ ៣៤

# បញ្ជីរូបភាព និងតារាង

**រូបភាព**

រូបភាព១ ៖ រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា ........ ១
រូបភាព២ ៖ ធនាគារ-ឥណទានតាមវិស័យសេដ្ឋកិច្ច ........ ៥
រូបភាព៣ ៖ ធនាគារ-ចំនួនគណនីឥណទាននិងគណនីប្រាក់បញ្ញើអតិថិជន ........ ៦
រូបភាព៤ ៖ ធនាគារ-ឥណទាននិងប្រាក់បញ្ញើអតិថិជន ........ ៦
រូបភាព៥ ៖ ធនាគារ-អនុបាតឥណទានមិនដំណើរការ ........ ៧
រូបភាព៦ ៖ មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម ........ ៩
រូបភាព៧ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទាននិងប្រាក់បញ្ញើ ........ ៩
រូបភាព៨ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច ........ ១០
រូបភាព៩ ៖ មីក្រូហិរញ្ញវត្ថុ-គុណភាពសំពៀតឥណទាន ........ ១០
រូបភាព១០ ៖ ចំនួនលិខិតអនុញ្ញាតប្តូរប្រាក់នៅតាមខេត្ត ........ ១៣
រូបភាព១១ ៖ ប្រភេទអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ ........ ១៣
រូបភាព១២ ៖ សំពៀតឥណទាន និងចំនួនគណនីអតិថិជនរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ... ២០
រូបភាព១៣ ៖ ការពិនិត្យរបាយការណ៍ឥណទាន ........ ២១
រូបភាព១៤ ៖ ប្រតិបត្តិការទីផ្សារអន្តរធនាគារ-និវាសជន ........ ២៧
រូបភាព១៥ ៖ ប្រតិបត្តិការទីផ្សារអន្តរធនាគារ-អនិវាសជន ........ ២៨
រូបភាព១៦ ៖ ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ . ២៨
រូបភាព១៧ ៖ លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ........ ២៩
រូបភាព១៨ ៖ ឥណទានទៅវិស័យអចលនទ្រព្យ ........ ៣០

**តារាង**

តារាង១ ៖ បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពីឆ្នាំ២០១៣-២០១៨ ........ ២
តារាង២ ៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក ........ ៣
តារាង៣ ៖ ការវិវឌ្ឍក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ) ........ ៥
តារាង៤ ៖ វិស័យភតិសន្យាហិរញ្ញវត្ថុ ........ ១១
តារាង៥ ៖ ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ ........ ១៤
តារាង៦ ៖ ការដាក់ចេញនូវវិធានរបស់ធនាគារជាតិនៃកម្ពុជា ........ ១៥
តារាង៧ ៖ លំហូរវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ........ ២៩

**ប្រអប់**

ប្រអប់១ ៖ សេចក្តីណែនាំស្តីពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ........ ២២
ប្រអប់២ ៖ បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ........ ២៤

# ទិន្នន័យទាំងអស់មិនទាន់ត្រូវបានធ្វើសវនកម្ម
# និងត្រូវបានរាយការណ៍ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍសំខាន់ៗនៃប្រព័ន្ធធនាគារ

### ១.១. និន្នាការទូទៅនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ឆ្នាំ២០១៨ សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលបានគាំទ្រដោយស្ថិរភាពនយោបាយក្នុងស្រុក។ កត្តារីកចម្រើននិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គឺជាកម្លាំងចលករយ៉ាងសំខាន់នៃការវិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយស្ថិរភាពនិងនិរន្តរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើនទាំងទំហំប្រតិបត្តិការ និងវិសាលភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប្រព័ន្ធធនាគាររួមមានគ្រឹះស្ថានធនាគារពាណិជ្ជ ៤៣ ធនាគារឯកទេស ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើពីសាធារណជន ៧៤ គ្រឹះស្ថានឥណទានជនបទ ២៧៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ១ ក្រុមហ៊ុនសវនកម្ម ១០ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៤ អ្នកដំណើរការតតិយភាគី ៥ អាជីវករប្តូរប្រាក់ ២.៧៧៩ និងការិយាល័យតំណាងធនាគារបរទេស ៥ (រូបភាព ១)។

*រូបភាព១ ៖ រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា*




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

តារាង១ ៖ បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពីឆ្នាំ២០១៤-២០១៨

| គ្រឹះស្ថានធនាគារ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ធនាគារពាណិជ្ជ | | | | | |
| **ធនាគារក្នុងស្រុក- ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | | |
| ចំនួនធនាគារ | ៧ | ៧ | ៧ | ៧ | ៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៣៥៤ | ៣៧៥ | ៣៨៣ | ៣៩៥ | ៤០៣ |
| ចំនួនបុគ្គលិក | ១៤.៨៩៦ | ១៦.២៣៩ | ១៧.០២៣ | ១៧.៦២៨ | ១៨.១៧១ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៤៥៤ | ៥៤៤ | ៥៧៤ | ៧១២ | ៨២៥ |
| **ធនាគារក្នុងស្រុក- ភាគទុនិកភាគច្រើនជាជនបរទេស** | | | | | |
| ចំនួនធនាគារ | ៦ | ៥ | ៥ | ៥ | ៦ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៤៧ | ៥៤ | ២២៥ | ២៤៤ | ២០១ |
| ចំនួនបុគ្គលិក | ១.៤៤៤ | ១.៧៣៨ | ៦.៣៨២ | ៧.៦០៧ | ៥.៩៧៣ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ១១៧ | ១៧៥ | ២៧៦ | ៣៥២ | ២០១ |
| **ធនាគារបុត្តសម្ព័ន្ធបរទេស** | | | | | |
| ចំនួនធនាគារ | ១២ | ១៤ | ១៤ | ១៥ | ១៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១១៩ | ១៤២ | ១៥០ | ១៥៧ | ២៣៩ |
| ចំនួនបុគ្គលិក | ២.៩៨៤ | ៣.៥២៩ | ៣.៦៣៩ | ៤.០០២ | ៨.៨១៧ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៣៥៨ | ៣៩១ | ៣៩៧ | ៤០៩ | ៧៦៩ |
| **ធនាគារសាខាបរទេស** | | | | | |
| ចំនួនធនាគារ | ១១ | ១០ | ១១ | ១២ | ១២ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ២១ | ២២ | ២៥ | ៣១ | ៣៣ |
| ចំនួនបុគ្គលិក | ៤៣៩ | ៤៦៣ | ៥៣០ | ៦២៦ | ៧១៣ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៦ | ៨ | ១៣ | ១៧ | ២៣ |
| **ចំនួនសរុបធនាគារពាណិជ្ជ** | | | | | |
| ចំនួនសរុបធនាគារ | **៣៦** | **៣៦** | **៣៧** | **៣៩** | **៤៣** |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | **៥៤១** | **៥៩៣** | **៧៨៣** | **៨២៧** | **៨៧៦** |
| ចំនួនសរុបបុគ្គលិក | **១៩.៧៦៣** | **២១.៩៦៩** | **២៧.៥៦៩** | **២៩.៨៦៣** | **៣៣.១៧៤** |
| ចំនួនសរុបទីតាំងម៉ាស៊ីន ATM | **៩៤០** | **១.១១៨** | **១.២៦០** | **១.៤៩០** | **១.៨១៨** |
| ធនាគារឯកទេស | | | | | |
| **ធនាគារឯកទេសរបស់រដ្ឋ** | | | | | |
| ចំនួនធនាគារ | ១ | ១ | ១ | ១ | ១ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១ | ១ | ១ | ១ | ១ |
| ចំនួនបុគ្គលិក | ៦៧ | ៧៥ | ៨៩ | ៩៣ | ១០១ |
| **ធនាគារឯកទេស- ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | | |
| ចំនួនធនាគារ | ៤ | ៣ | ៥ | ៥ | ៦ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៧ | ៧ | ១០ | ១០ | ១១ |
| ចំនួនបុគ្គលិក | ១៧៨ | ៤០៧ | ៥១៨ | ៥១០ | ៥៧៣ |
| **ធនាគារឯកទេស- ភាគទុនិកភាគច្រើនជាជនបរទេស** | | | | | |
| ចំនួនធនាគារ | ៦ | ៧ | ៩ | ៩ | ៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៨ | ១៣ | ១៨ | ១៨ | ១៨ |
| ចំនួនបុគ្គលិក | ២៦៥ | ៣៨១ | ៨៦២ | ៩៧៩ | ១.២៥០ |
| **ចំនួនសរុបធនាគារឯកទេស** | | | | | |
| ចំនួនសរុបធនាគារ | **១១** | **១១** | **១៥** | **១៥** | **១៤** |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | **១៦** | **២១** | **២៩** | **២៩** | **៣០** |
| ចំនួនសរុបបុគ្គលិក | **៥១០** | **៨៦៣** | **១.៤៦៩** | **១.៥៨២** | **១.៩២៤** |

| | | | | | |
|---|---|---|---|---|---|
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | | |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | | |
| ចំនួនគ្រឹះស្ថាន | ៧ | ៨ | ៧ | ៧ | ៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១.៣៨៣ | ១.៦៣២ | ១.៤៥៦ | ៩៤៦ | ៩២៨ |
| ចំនួនបុគ្គលិក | ១៥.៥៧៦ | ២០.៨០៨ | ១៩.៩៨៧ | ២១.៦៧១ | ២៣.២៨៥ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ១៩៧ | ២៩៨ | ៣០៧ | ៣៥០ | ៣៥៥ |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ** | | | | | |
| ចំនួនគ្រឹះស្ថាន | ៣២ | ៥០ | ៦៤ | ៦៩ | ៧៤ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១.៣១១ | ២.១៨៦ | ២.៦៩៨ | ៤៧១ | ៤៩៥ |
| ចំនួនបុគ្គលិក | ៤.០១៤ | ៥.៤៦០ | ៦.៥៨១ | ៦.៦៣១ | ៦.៨៩៧ |
| **ចំនួនសរុបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | | |
| ចំនួនសរុបគ្រឹះស្ថាន | **៣៩** | **៥៨** | **៧១** | **៧៦** | **៨១** |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | **២.៦៩៤** | **៣.៨១៨** | **៤.១៥៤** | **១.៤១៧** | **១.៤២៣** |
| ចំនួនសរុបបុគ្គលិក | **១៩.៥៩០** | **២៦.២៦៨** | **២៦.៥៦៨** | **២៨.៣០២** | **៣០.១៨២** |
| ចំនួនសរុបទីតាំងម៉ាស៊ីន ATM | **១៩៧** | **២៩៨** | **៣០៧** | **៣៥០** | **៣៥៥** |
| **គ្រឹះស្ថានឥណទានជនបទ** | | | | | |
| ចំនួនសរុបគ្រឹះស្ថាន | **៣៨** | **១០៩** | **១៧០** | **៣១៣** | **២៧៣** |
| ចំនួនសរុបបណ្តាញប្រតិបត្តិការ | **៥០៩** | **១.៧១៥** | **២.០៨៣** | **៣.៣៦៦** | **២.៩៣៦** |
| ចំនួនសរុបបុគ្គលិក | **៩៤២** | **៣.២៥៥** | **៣.៦៧០** | **៥.១២៣** | **៤.៤៦៨** |
| **ក្រុមហ៊ុនភតិសន្យា** | | | | | |
| ចំនួនសរុបក្រុមហ៊ុន | **៦** | **៩** | **១២** | **១១** | **១៥** |
| **ការិយាល័យតំណាងធនាគារបរទេស** | | | | | |
| ចំនួនសរុបការិយាល័យ | **៧** | **៨** | **៧** | **៦** | **៥** |
| **ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា** | | | | | |
| ចំនួនសរុបក្រុមហ៊ុន | **១** | **១** | **១** | **១** | **១** |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## តារាង២ ៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-១៧ | ធ្នូ-១៨ | ធ្នូ-១៧ | ធ្នូ-១៨ | ធ្នូ-១៧ | ធ្នូ-១៨ | ធ្នូ-១៧ | ធ្នូ-១៨ |
| **ធនាគារពាណិជ្ជ** | | | | | | | | |
| ធនាគារបរទេស | ៥៥,៤% | ៤៩,២% | ៥៥,១% | ៤៧,៨% | ៥២,៨% | ៤៦,៦% | ៦២,៥% | ៥៣,៦% |
| ធនាគារក្នុងស្រុក | ៤២,៦% | ៤៩,០% | ៤២,៥% | ៤៩,៨% | ៤៧,២% | ៥៣,៣% | ២៩,៧% | ៣៨,៩% |
| **ធនាគារឯកទេស** | | | | | | | | |
| ធនាគារបរទេស | ១,១% | ០,៩% | ១,៣% | ១,៣% | ០,០% | ០,០% | ៤,១% | ៤,០% |
| ធនាគារក្នុងស្រុក | ០,៩% | ០,៩% | ១,១% | ១,១% | ០,០% | ០,០% | ៣,៨% | ៣,៥% |
| **សរុប** | | | | | | | | |
| ធនាគារបរទេស | ៥៦,៥% | ៥០,១% | ៥៦,៤% | ៤៩,១% | ៥២,៨% | ៤៦,៧% | ៦៦,៦% | ៥៧,៦% |
| ធនាគារក្នុងស្រុក | ៤៣,៥% | ៤៩,៩% | ៤៣,៦% | ៥០,៩% | ៤៧,២% | ៥៣,៣% | ៣៣,៤% | ៤២,៤% |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ២២,៥% (ឆ្នាំលើឆ្នាំ) ដល់ ១៦៧,៣ ទ្រីលានរៀល ដែលក្នុងនោះកំណើនឥណទាន ២៤,៤% ដល់ ១០៣,៨ ទ្រីលានរៀល។ កំណើនទាំងនេះបានគាំទ្រដោយកំណើនមូលនិធិកម្ម ៧,៤% ដល់ ១៤,៧ ទ្រីលានរៀល ដើមទុនរបស់សាមីគ្រឹះស្ថាន ២៣,៦% ដល់ ៣១,៨ ទ្រីលានរៀល ប្រាក់បញ្ញើរបស់អតិថិជន ២៨,៧% ដល់ ៩៩,៩ ទ្រីលានរៀល។ ចំនួនគណនីប្រាក់បញ្ញើបានកើនដល់ ៦,៣ លានគណនី និងចំនួនគណនីអ្នកខ្ចីប្រាក់ដល់ ២,៨ លានគណនី។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តសកម្មភាពយ៉ាងសកម្ម ក្នុងការឆ្លើយតបទៅនឹងតម្រូវការសេវាហិរញ្ញវត្ថុរបស់អតិថិជនសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ជាក់ស្តែង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបាននិងបន្តពង្រីកវិសាលភាពសេវាកម្ម និងបណ្តាញប្រតិបត្តិការនៅតាមរាជធានី-ខេត្ត ដោយមានបណ្តាញសាខាកើនដល់ ២.៣២៨ សាខា ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ២.១៧៣ ម៉ាស៊ីន។ ទន្ទឹមនេះ ការប្រើប្រាស់បណ្ណជំនួសសាច់ប្រាក់ និងការផ្តល់សេវាផ្ទេរប្រាក់និងការទូទាត់សងប្រាក់អេឡិចត្រូនិក ត្រូវបានដាក់ឲ្យប្រើប្រាស់យ៉ាងទូលំទូលាយ និងមានភាពងាយស្រួល។

គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏បានរក្សានូវភាពគ្រប់គ្រាន់នៃដើមទុន និងសន្ទនីយភាពរឹងមាំ ដែលបានបង្ហាញតាមរយៈអនុបាតសាធនភាពជាមធ្យមប្រមាណ ២៤,២% និង ១៩.៨% និងអនុបាតសន្ទនីយភាពប្រមាណ ១៥៨.៨% និង ២១៣.៦% រៀងគ្នា។ ជាមួយគ្នានេះ គ្រឹះស្ថានបានគ្រប់គ្រងឥណទានប្រកបដោយគុណភាព ដែលបានឆ្លុះបញ្ចាំងតាមរយៈការរក្សាអនុបាតឥណទាន មិនដំណើរការក្នុងកម្រិតទាបជាមធ្យមប្រមាណ ២,២% សម្រាប់គ្រឹះស្ថានធនាគារ និង ១,៣% សម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

### ១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ

តាមរយៈទំនាក់ទំនងជិតស្និទ្ធនៃវិស័យធនាគារនិងសេដ្ឋកិច្ចរូបវន្ត វិស័យធនាគារនៅតែបន្តដើរតួនាទីសំខាន់ក្នុងការគាំទ្រ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម។ ប្រតិបត្តិការនៃវិស័យធនាគារកាន់តែមានវិសាលភាពធំទូលាយ និងប្រទាក់ក្រឡាជាងមុន ដែលជាលទ្ធផលទ្រព្យសកម្មនិងឥណទានសរុបរបស់គ្រឹះស្ថានធនាគារបានកើនឡើងដល់ ១៣៩,៧ ទ្រីលានរៀល និង ៨១,៧ ទ្រីលានរៀល រៀងគ្នា ដែលស្មើនឹង ១៤៣,៦% និង ៨៣,៥% នៃផលិតផលក្នុងស្រុកសរុប។ កំណើនទ្រព្យសកម្មនិងឥណទានរបស់ធនាគារមានកម្រិត ២១,៤% និង ២៤,៣% រៀងគ្នា ដែលខ្ពស់ជាងឆ្នាំ២០១៧។

តារាង៣ ៖ ការវិវឌ្ឍក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ)

| ការវិវឌ្ឍក្នុងវិស័យធនាគារ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២៧,១% | ២៣,២% | ២០,៩% | ២០,១% | ២១,៤% |
| កំណើនឥណទាន | ២៧,១% | ២៥,៧% | ២០,៥% | ១៧,២% | ២៤,៣% |
| កំណើនប្រាក់បញ្ញើ | ២៨,៩% | ១៧,៤% | ២១,៨% | ២៥,១% | ២៧,៩% |
| ទ្រព្យសកម្មធៀបផ.ស.ស | ៩៨,៣% | ១០៧,៩% | ១១៨,២% | ១៤២,០% | ១៤៣,៦% |
| ឥណទានធៀបផ.ស.ស | ៥៦,៧% | ៦៣,៥% | ៦៨,៨% | ៨០,៧% | ៨៣,៥% |
| ប្រាក់បញ្ញើធៀបផ.ស.ស | ៥៩,២% | ៦១,៩% | ៦៨,៤% | ៨៥,៦% | ៩១,១% |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចនៅតែបន្តទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ តាមរយៈឥណទានពីគ្រឹះស្ថានធនាគារ មានដូចជា ការជួញដូររាយនិងដុំ ២៧,៥% ទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១០,១% កសិកម្ម ៨,៩% សំណង់ ៩,២% និងវិស័យផ្សេងៗ ៤៤,៣%។ ចាប់តាំងពីដំណាច់ឆ្នាំ២០១៦ គ្រឹះស្ថានធនាគារបន្តបង្កើនការផ្តល់ឥណទានជាប្រាក់រៀល ស្របតាមប្រកាសស្តីពីការផ្តល់ឥណទានជារូបិយវត្ថុជាតិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតម្រូវឲ្យគ្រឹះស្ថានទាំងអស់ត្រូវមានឥណទានជារូបិយវត្ថុជាតិយ៉ាងតិច ១០% នៃសំពៀតឥណទានសរុប ដែលនឹងអនុវត្តពេញលេញនៅដំណាច់ឆ្នាំ២០១៩ ខាងមុខនេះ។ ផលធៀបឥណទានអតិថិជនជារៀលទៅនឹងឥណទានសរុបរបស់គ្រឹះស្ថានធនាគារបន្តកើនឡើងជាបន្តបន្ទាប់ពី ១,៩% ក្នុងឆ្នាំ២០១៧ ដល់ ៤,២% ក្នុងឆ្នាំ២០១៨។

រូបភាព៧២ ៖ ធនាគារ-ឥណទានតាមវិស័យសេដ្ឋកិច្ច




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនឹងការកើនឡើងនៃទ្រព្យសកម្មនិងឥណទាន កំណើនប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារកើនឡើង ២៧,៩% (កំណើនឆ្នាំលើឆ្នាំ) ដល់ ៨៨,៧ ទ្រីលានរៀល។ គ្រឹះស្ថានធនាគារបន្តកេណ្ឌ

ប្រមូលប្រាក់បញ្ញើពីសាធារណជនកាន់តែច្រើន ដែលនេះក៏ឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា តាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងស្រទាប់ជាជន។

**រូបភាព៣ ៖ ធនាគារ-ចំនួនគណនីឥណទាន និងប្រាក់បញ្ញើអតិថិជន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

គួរកត់សម្គាល់ផងដែរថា ប្រាក់បញ្ញើអតិថិជនជារៀលធៀបនឹងប្រាក់បញ្ញើអតិថិជនសរុបនៅគ្រឹះស្ថានធនាគារ បន្តកើនឡើងជាបន្តបន្ទាប់ពី ៥,៩% ក្នុងឆ្នាំ២០១៧ ដល់ ៦,១% ក្នុងឆ្នាំ២០១៨ ដែលនេះជាសញ្ញាណវិជ្ជមាននៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា លើការងារលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ចំនួនគណនីប្រាក់បញ្ញើកើនដល់ ៤.២០៩.៥៣៥ គណនី ដែល ៤២,៥% គ្រប់គ្រងដោយស្ត្រី ៥៣,២% គ្រប់គ្រងដោយបុរស និង ៤,៣% គ្រប់គ្រងដោយនីតិបុគ្គល។ ភាគច្រើននៃអ្នកដាក់ប្រាក់បញ្ញើ រួមមាន ឯកត្តជន ៥៤,៩% សហគ្រាសអាជីវកម្ម ២២,៦% គ្រឹះស្ថានធនាគារក្នុងស្រុកនិងក្រៅប្រទេស ៩,៧% និងគ្រឹះស្ថានផ្សេងៗ ១២,៨%។

**រូបភាព៤ ៖ ធនាគារ-ឥណទាន និងប្រាក់បញ្ញើអតិថិជន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់វិស័យធនាគារបន្តអភិវឌ្ឍជាលំដាប់ តាមរយៈការពង្រីកបណ្តាញប្រតិបត្តិការបន្ថែម ដោយការបើកសាខាថ្មី ៤៩ សាខា និងការដាក់ឲ្យប្រើប្រាស់នូវម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ថ្មី ៣៣៣ ម៉ាស៊ីន។ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យានិងភាពល្អប្រសើរនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការប្រើប្រាស់បណ្ណជំនួសសាច់ប្រាក់ (បណ្ណឥណទាន ១០២.១៥១ បណ្ណ និងបណ្ណឥណពន្ធ ២.១៧២.២៦៣ បណ្ណ) សរុបមាន ៦១,២ ទ្រីលានរៀល ដែលកើនឡើង ២៧,៩% (ឆ្នាំលើឆ្នាំ)។

អនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា សុខុមាលភាពរបស់វិស័យធនាគារមានភាពល្អប្រសើរ និងរក្សាបានលើសកម្រិតកំណត់ ដោយអនុបាតសាធនភាពនិងអនុបាតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារមានកម្រិត ២៤,២% និង ១៥៨,៧% រៀងគ្នា។ ទន្ទឹមនេះ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មមាន ១,៦% និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុនមាន ៨,៥%។ ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់ខ្ពស់លើការត្រួតពិនិត្យប្រតិបត្តិការគ្រឹះស្ថានធនាគារ ដើម្បីរក្សាឲ្យបាននូវភាពរឹងមាំនិងសុវត្ថិភាពរបស់ប្រព័ន្ធធនាគារទាំងមូល ជាពិសេស អភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុង និងគុណភាពទ្រព្យសកម្ម ជាដើម។ ជាក់ស្តែង គ្រឹះស្ថានធនាគារបានគ្រប់គ្រងការផ្តល់ឥណទានមានប្រសិទ្ធភាព ដោយរក្សាបានអនុបាតឥណទានមិនដំណើរការក្នុងកម្រិត ២,២%។ ការដាក់ចេញនូវប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិនរបស់ធនាគារជាតិនៃកម្ពុជា ក្នុងឆ្នាំ២០១៧ បានជួយពង្រឹងបន្ថែមការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ននិងគ្រប់ជ្រុងជ្រោយ។

**រូបភាព៥ ៖ ធនាគារ-អនុបាតឥណទានមិនដំណើរការ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ការរាយការណ៍អំពីអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានគណនាតាមវិធីសាស្ត្រអត្រាការប្រាក់ជាមធ្យមថ្លឹង (Weighted Average Interest Rate) ដោយគិតតាមប្រភេទនិងឥណប្រតិទាននៃប្រាក់បញ្ញើ និងឥណទាន ដែលបានព្រមព្រៀងដោយធនាគារនិងអតិថិជន។ ជាលទ្ធផល

អត្រាការប្រាក់ឥណទានជាមធ្យមក្នុងមួយឆ្នាំមាន ១៥,៩% ចំពោះឥណទានជាប្រាក់រៀល និង ១០,៦% ចំពោះឥណទានជាប្រាក់ដុល្លារអាមេរិក។ អត្រាការប្រាក់ឥណទានជាប្រាក់រៀលនិងដុល្លារអាមេរិក មាននិន្នាការធ្លាក់ចុះពី ១៧,១% និង ១១,៨% ក្នុងខែមករា មក ១៤,៨% និង ១០,៩% ក្នុងខែធ្នូ រៀងគ្នា។ ការធ្លាក់ចុះនៃអត្រាការប្រាក់នេះមានកត្តារួមចំណែកមួយចំនួន ដូចជា កម្រិតប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ការបង្កើនសំពៀតឥណទានជារូបិយវត្ថុជាតិ ១០% នៃសំពៀតឥណទានសរុប ការទទួលបានមូលនិធិវិនិយោគពីធនាគារជាតិនៃកម្ពុជាតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងកំណើនការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជាដើម។ ចំណែកអត្រាការប្រាក់បញ្ញើជាមធ្យមក្នុងមួយឆ្នាំ មាន ៦,៤% ជាប្រាក់រៀល និង ៤,៩% ជាប្រាក់ដុល្លារអាមេរិក ដោយនិន្នាការអត្រាការប្រាក់បញ្ញើមានស្ថានភាពកើនឡើងបន្តិច ទាំងជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក ពោលគឺពី ៦,២% និង ៤,៥% ក្នុងខែមករា ទៅ ៦,៣% និង ៤,៩% ក្នុងខែធ្នូ រៀងគ្នា។

### ១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបន្តរីកចម្រើនគួរឲ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន ៨១ ដែល ៧ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៧៤ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុ ស្របតាមលក្ខខណ្ឌគតិយុត្តិរបស់សាមីគ្រឹះស្ថាននីមួយៗ ដូចជា ការផ្តល់ឥណទាន សេវាផ្ទេរប្រាក់ សេវាធនាគារចល័ត សេវាម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) និងសេវាទទួលប្រាក់បញ្ញើ ជាដើម។

ការរួមចំណែករបស់វិស័យមីក្រូហិរញ្ញវត្ថុ ពិតជាមានសារៈសំខាន់ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងបានចូលរួមចំណែកយ៉ាងសកម្មដល់ការជំរុញបរិយាប័ន្នហិរញ្ញវត្ថុក្នុងប្រព័ន្ធធនាគារកម្ពុជា។ បណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានគ្របដណ្តប់ទូទាំង ២៥ ខេត្ត-ក្រុង ដោយក្នុងនោះការិយាល័យនៅរាជធានីភ្នំពេញមាន ៧៥ នៅថ្នាក់ខេត្ត-ក្រុង ៣៩៩ និងនៅថ្នាក់ស្រុក ៩៤៤ និងបានផ្តល់ការងារដល់បុគ្គលិក ៣០.១៨២ នាក់ ក្នុងនោះស្ត្រីមាន ៨.៤០២ នាក់។

ទំហំទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកើនឡើងដល់ ២៦,៦ ទ្រីលានរៀល ស្មើនឹង ២៧,៤% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងមានកំណើនផលធៀបឆ្នាំលើឆ្នាំស្មើនឹង ៣១,២%។ ស្របជាមួយគ្នានេះដែរ ប្រាក់បញ្ញើនិងឥណទានអតិថិជនក្នុងវិស័យមីក្រូហិរញ្ញវត្ថុក៏បានកើនឡើងជាបន្តបន្ទាប់ដល់ ១១,៣ ទ្រីលានរៀល និង ២១,៨ ទ្រីលានរៀល រៀងគ្នា។

**រូបភាព១៦ ៖ មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ការកើនឡើងនៃទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទាន ឆ្លុះបញ្ចាំងពីកំណើននៃការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុកាន់តែច្រើនជាងមុន ក៏ដូចជាការគាំទ្រនិងជំនឿទុកចិត្តរបស់សាធារណជនមកលើវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា។ ភាគច្រើន នៃប្រាក់បញ្ញើនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨៦% ជាបញ្ញើខ្នាតតូច ដែលមានទំហំទឹកប្រាក់តិចជាង ២៥០ ពាន់រៀល។ ឥណទានតាមវិស័យសំខាន់ៗក្នុង សេដ្ឋកិច្ច រួមមាន ក្រុមគ្រួសារ ៣៦,៧% កសិកម្ម ២១,១% ការជួញដូរនិងពាណិជ្ជកម្ម ១៧,៦% សេវាកម្ម ១០,៩% សំណង់និងដឹកជញ្ជូន ៩,២% និងផ្សេងៗ ៤,៥%។

**រូបភាព១៧ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទាននិងប្រាក់បញ្ញើ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ប្រជាជនតាមទីជនបទកាន់តែច្រើនបានងាកមកប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ដែលរួមចំណែកយ៉ាងខ្លាំងដល់ការលើកកម្ពស់ទម្លាប់សន្សំប្រាក់ និងកម្រិតជីវភាពរស់នៅតាមរយៈការទទួល

បានប្រភពទុនសម្រាប់អាជីវកម្មខ្នាតតូចនិងមធ្យមរបស់ប្រជាជន។ ស្ត្រីនៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានបន្តកើនឡើងដល់ ២,១ លានគណនី និង ១,៩ លានគណនី រៀងគ្នា ក្នុងនោះមានស្ត្រីលើសពី ៧០% ជាម្ចាស់គណនី។

**រូបភាព៨ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ជារួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តគោរពបានតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតសាធនភាព និងអនុបាតសន្ទនីយភាពមានកម្រិត ១៩,៨% និង ២១៣,៦% រៀងគ្នា ដែលរក្សាបានលើសកម្រិតកំណត់។ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុនមានកម្រិត ២,៧% និង ១៣,៥% រៀងគ្នា។ រីឯអនុបាតឥណទានមិនដំណើរការមានកម្រិត ១,៣%។

**រូបភាព៩ ៖ មីក្រូហិរញ្ញវត្ថុ-គុណភាពសំពៀតឥណទាន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

អត្រាការប្រាក់ឥណទានជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តធ្លាក់ចុះជាលំដាប់ ដោយអត្រាការប្រាក់ឥណទានជារៀលមាន ១៧,៦% និងជាដុល្លារអាមេរិកមាន ១៥,៩% ខណៈដែលអត្រាការប្រាក់បញ្ញើជាមធ្យមបានកើនឡើងបន្តិចដល់ ៧,៩% ទាំងជារៀលនិងដុល្លារអាមេរិក។ ប្រតិបត្តិការ LPCO ជាផ្នែកមួយជួយដោះស្រាយបញ្ហាកង្វះសន្ទនីយភាពជាប្រាក់រៀល ដោយបានបង្កើនប្រភពមូលនិធិជាប្រាក់រៀលក្នុងសេដ្ឋកិច្ច និងកាត់បន្ថយគម្លាតរវាងអត្រាការប្រាក់ឥណទានជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកឲ្យមានកម្រិតទាប។ កំណើននៃការប្រកួតប្រជែងកាន់តែសកម្មនៅក្នុងទីផ្សារ ក៏ជួយកាត់បន្ថយអត្រាការប្រាក់ឥណទានទាំងជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកឆ្លុះបញ្ចាំងតាមរយៈប្រសិទ្ធភាពនៃប្រតិបត្តិការ (កាត់បន្ថយចំណាយប្រតិបត្តិការនិងឥណទានមិនដំណើរការ) និងការកេណ្ឌប្រមូលប្រភពទុនក្នុងស្រុកនិងក្រៅស្រុក។

### ១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ

ស្របតាមការកើនឡើងនៃកម្រិតជីវភាពរស់នៅ ក៏ដូចជាតម្រូវការរបស់ក្រុមគ្រួសារ វិស័យភតិសន្យាហិរញ្ញវត្ថុបាននិងកំពុងជំរុញប្រតិបត្តិការរបស់ខ្លួន ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុលើចលនទ្រព្យ ដូចជា ម៉ូតូ រថយន្ត គ្រឿងយន្តប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រឿងចក្រក្នុងវិស័យសំណង់ គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ក្នុងគ្រួសារ និងចលនទ្រព្យមួយចំនួនទៀតទៅតាមតម្រូវការរបស់អតិថិជន។ ទំហំប្រតិបត្តិការ និងទីផ្សារសេវាភតិសន្យាហិរញ្ញវត្ថុបន្តរីកដុះដាលពីមួយឆ្នាំទៅមួយឆ្នាំ ដោយក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុថ្មីចំនួន ៤ បានចាប់ដំណើរការបន្ថែមពីលើក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១១ ដែលកំពុងមានវត្តមានក្នុងទីផ្សារកម្ពុជា។

*តារាង៤ ៖ វិស័យភតិសន្យាហិរញ្ញវត្ថុ*

(គិតជាប៊ីលានរៀល)

| ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ចំនួនទ្រព្យសកម្មសរុប | ១៨៦,៣ | ៤១០,៤ | ៦២២,៨ | ៧០៧,៩ | ៩៥១,៦ |
| ចំនួនឥណទានសរុប | ១៤៧,១ | ៣៩៤,៩ | ៤៨៥,០ | ៥២៥,៣ | ៧១៣,៨ |
| ឥណទានមិនដំណើរការ | ៣,២% | ៥,៣% | ៥,៩% | ៥,៣% | ៨,៤% |
| មូលនិធិផ្ទាល់សុទ្ធ | ៣៩,៤ | ៩៩,០ | ១១៣,៣ | ១៧៣,៥ | ៣៣៥,២ |
| ចំនួនបុគ្គលិក (នាក់) | ៥៩៥ | ៨៥៧ | ១.២៩៥ | ១.២៦៦ | ១.៣៦១ |
| ចំនួនអតិថិជន (នាក់) | ១៨.៦៨៣ | ៤៣.៩១៣ | ៦១.៣៧២ | ៦៤.២៥២ | ៧២.៩២១ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានកើនឡើងដល់ ៩៥១,៦ ប៊ីលានរៀល និងភតិសន្យាហិរញ្ញវត្ថុ សរុបកើនឡើងដល់ ៧១៣,៨ ប៊ីលានរៀល ដែលសេវាភតិសន្យាហិរញ្ញវត្ថុទាំងនេះត្រូវបានផ្តល់ដល់អតិថិជន ៧២.៩២១ គណនី។ សេវាភតិសន្យាហិរញ្ញវត្ថុត្រូវបានបែងចែក

វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច មានដូចជា ក្រុមគ្រួសារ ៥៥,៦% កសិកម្ម ៧,៥% សំណង់ ៧,២% ពាណិជ្ជកម្ម ៦,៧% ការដឹកជញ្ជូន ៩,៣% សេវាកម្ម ៦,០% និងផ្សេងៗ ១៨,៧%។

### ១.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ

ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្ដីពី ការផ្ដល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ដើម្បីកំណត់លក្ខខណ្ឌនៃការទទួលបានវិញ្ញាបនបត្រ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យគ្រឹះស្ថានដែលផ្ដល់ឥណទានខ្នាតតូច។ ធនាគារជាតិនៃកម្ពុជានៅតែបន្តការដាក់ចេញបទប្បញ្ញត្តិ ការត្រួតពិនិត្យទាំងលើឯកសារនិងដល់ទីកន្លែងចំពោះគ្រឹះស្ថានឥណទានជនបទ លើការផ្ដល់សេវាហិរញ្ញវត្ថុផ្លូវការជូនប្រជាពលរដ្ឋ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងតាមដានជនឆ្លៀតឱកាស និងគ្រឹះស្ថានឥណទានជនបទមួយចំនួនតូច ដែលបាននិងកំពុងអូសទាញប្រជាពលរដ្ឋ តាមរយៈការកេណ្ឌប្រមូលប្រាក់បញ្ញើក្រោមរូបភាព "កិច្ចសន្យាខ្ចីប្រាក់ ឬ ការវិនិយោគដើមទុន" ដោយផ្ដល់អត្រាចំណេញខ្ពស់។ ជាលទ្ធផល គ្រឹះស្ថានឥណទានជនបទសរុបមាន ២៧៣ គ្រឹះស្ថាន ដែលមានទ្រព្យសកម្មសរុប ៥៩៩,៨ ប៊ីលានរៀល ក្នុងនោះសមតុល្យឥណទានសរុប ៤៩០,៦ ប៊ីលានរៀល ដោយបានបែងចែកទៅវិស័យកសិកម្ម ៣១,៨% ពាណិជ្ជកម្ម ១៧,៧% ក្រុមគ្រួសារ ២០,២% សេវាកម្ម ១២,១% ដឹកជញ្ជូន ១,៩% សំណង់ ៧% និងផ្សេងៗ ៩,៥%។ គ្រឹះស្ថានឥណទានជនបទបានផ្ដល់ឥណទានដល់អតិថិជន ២១១.៧៥៧ គណនី និងមានអនុបាតឥណទានមិនដំណើរការ ១១,៩% ដែលជាលទ្ធផលនៃការគ្រប់គ្រងឥណទានពុំទាន់មានប្រសិទ្ធភាពល្អ។

### ១.២.៥. ប្រតិបត្តិការនៃអាជីវកម្មប្ដូរប្រាក់

ការចេញនូវសេចក្ដីជូនដំណឹងលេខ ធ៧-០១៧-១០៤៨ ស.ជ.ណ ចុះថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ មានគោលបំណងជំរុញការអនុវត្តប្រកាសស្ដីពី *"ការផ្ដល់អាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្ដូរប្រាក់"* ដល់អាជីវករប្ដូរប្រាក់ដែលកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជា ដើម្បីបំពេញកាតព្វកិច្ចក្នុងការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណប្រកបអាជីវកម្មប្ដូរប្រាក់ពីធនាគារជាតិនៃកម្ពុជា។ ទន្ទឹមនេះ នីតិបុគ្គល ឬ រូបវន្តបុគ្គលដែលមានបំណងប្រកបអាជីវកម្មប្ដូរប្រាក់ ក៏តម្រូវឲ្យមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា មុននឹងដំណើរការអាជីវកម្មរបស់ខ្លួន។ អាជីវករប្ដូរប្រាក់សរុបមាន ២.៧៧៩ ដែលក្នុងនោះអាជ្ញាបណ្ណចំពោះក្រុមហ៊ុននិងអាជីវករប្ដូរប្រាក់ ២៣ គ្រឹះស្ថានធនាគារ ២៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២៥ ព្រមទាំងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្ដូរប្រាក់ ២.៧០៦។

**រូបភាព១០ ៖ ប្រភេទអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**រូបភាព១១ ៖ ចំនួនលិខិតអនុញ្ញាតប្តូរប្រាក់នៅតាមខេត្ត**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

# ២. ការវិវឌ្ឍក្របខណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ

## ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

ស្របតាមការរីកចម្រើននៃប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបង្កើនការត្រួតពិនិត្យ តាមរយៈការពិនិត្យឡើងវិញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដើម្បីធានាបាននូវភាពរឹងមាំក្នុងប្រព័ន្ធធនាគារ ពោលគឺការពង្រឹងសុខុមាលភាពរបស់គ្រឹះស្ថាននិងកិច្ចគាំពារអតិថិជន។ ស្ថិតក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានដាក់ចេញនូវវិធានសមស្របមួយចំនួនដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត រួមមាន៖

១. សេចក្តីជូនដំណឹងលេខ ធ៧-០១៨-១៣០ ស.ជ.ណ. ចុះថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ការដាក់ឲ្យអនុវត្តនូវទម្រង់របាយការណ៍អត្រាការប្រាក់មធ្យមថ្លឹងចំពោះប្រាក់បញ្ញើនិងឥណទាន"
២. សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃសុក្រ ២ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ការអនុវត្តប្រកាសស្តីពីចំណាត់ ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន"
៣. ប្រកាសលេខ ធ៧-០១៨-០៦៨ ប្រ.ក ចុះថ្ងៃព្រហស្បតិ៍ ៨ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ការកំណត់ទុនអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"
៤. សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.ក.ណ ចុះថ្ងៃពុធ ៦ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ស្តីពី "ការអនុវត្តប្រកាសស្តីពី ការកំណត់ទុនអប្បបរមា ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ"
៥. វិសោធនកម្មប្រកាសលេខ ធ៧-០១៨-២៨២ ប្រ.ក. ចុះថ្ងៃពុធ ៣ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពី "ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ"។

**តារាង៥ ៖ ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

| ប្រភេទគ្រឹះស្ថាន | កម្រិតដើមទុនអប្បបរមា |
|---|---|
| ធនាគារពាណិជ្ជបង្កើតក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេ មានចំណាត់ថ្នាក់វិនិយោគ | ២០០.០០០.០០០.០០០ (ពីររយប៊ីលានរៀល) |
| ធនាគារពាណិជ្ជបង្កើតក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុត្តសម្ព័ន្ធធនាគារបរទេស | ៣០០.០០០.០០០.០០០ (បីរយប៊ីលានរៀល) |
| ធនាគារឯកទេសបង្កើតក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក | ៦០.០០០.០០០.០០០ (ហុកសិបប៊ីលានរៀល) |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ១២០.០០០.០០០.០០០ (មួយរយម្ភៃប៊ីលានរៀល) |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | ៦.០០០.០០០.០០០ (ប្រាំមួយប៊ីលានរៀល) |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

តារាង៦ ៖ ការដាក់ចេញនូវវិធានរបស់ធនាគារជាតិនៃកម្ពុជា

| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| **ដើមទុន** | | | | | |
| ដើមទុនចុះបញ្ជីអប្បរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | | ៥០% (មីនា) | ១០០% (មីនា) | | |
| ទ្រនាប់ដើមទុនខោនស៊ើវេសិន | | | | ≥៥០% (មករា) | ១០០% (មករា) |
| អនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល | | | អនុញ្ញាត ០% (មីនា) | | |
| **អនុបាតក្របខណ្ឌសន្ទនីយភាព** | | | | | |
| គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៦០% (កញ្ញា) | ៧០% (កញ្ញា) | ៨០% (កញ្ញា) | ៩០% (មិថុនា) | ១០០% (មករា) |
| **ក្របខណ្ឌឥណទាន** | | | | | |
| ផ្តល់ឥណទានជារូបិយវត្ថុជាតិ (អប្បបរមា ១០% នៃឥណទានសរុប) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | | | | ១០០% (ធ្នូ) | |
| ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន | | ចាប់អនុវត្ត (ធ្នូ) | | | |
| ការកំណត់ពិដានអត្រាការប្រាក់ឥណទាន ១៨% ចំពោះគ្រឹះស្ថាមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានឥណទានជនបទ | | ចាប់អនុវត្ត (មេសា) | | | |
| **ការផ្តល់អាជ្ញាបណ្ណ** | | | | | |
| គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា | | ចាប់អនុវត្ត (កញ្ញា) | | | |
| ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | ចាប់អនុវត្ត (មិថុនា) | | | |
| ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ | | ចាប់អនុវត្ត (តុលា) | | | |
| **កិច្ចគាំពារអតិថិជន** | | | | | |
| ដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | | ចាប់អនុវត្ត (កញ្ញា) | | | |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ២.១.១. ការដាក់ឲ្យអនុវត្តនូវទម្រង់របាយការណ៍អត្រាការប្រាក់មធ្យមថ្លឹងចំពោះប្រាក់បញ្ញើនិងឥណទាន

ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត នូវការគណនាអត្រាការប្រាក់ថ្មី យោងតាមសេចក្ដីជូនដំណឹងលេខធ៧-០១៨-១៣០ ស.ជ.ណ. ចុះថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីការដាក់ឲ្យអនុវត្តនូវទម្រង់របាយការណ៍អត្រាការប្រាក់មធ្យមថ្លឹងចំពោះប្រាក់បញ្ញើនិងឥណទាន។ ការគណនាអត្រាការប្រាក់ថ្មីនេះ ត្រូវបានគណនាតាមវិធីសាស្ត្រអត្រាការប្រាក់មធ្យមថ្លឹង (Weighted Average Interest Rate) ដើម្បីបង្កើនគុណភាពនៃការតាមដាន និងការវិភាគស្ថានភាពអត្រាការប្រាក់នៅក្នុងប្រព័ន្ធធនាគារឲ្យកាន់តែមានសង្គតិភាពនិងប្រសិទ្ធភាព។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្ដីណែនាំអំពីការរៀបចំរបាយការណ៍នេះ ដោយពន្យល់អំពីនិយមន័យពាក្យបច្ចេកទេសនៅក្នុងទម្រង់របាយការណ៍ថ្មី និងរបៀបគណនាអត្រាការប្រាក់ថ្លឹងលើប្រាក់កម្ចីថ្មីនិងប្រាក់បញ្ញើថ្មីដោយភ្ជាប់មកជាមួយឧទាហរណ៍ជាក់ស្ដែង ក្នុងគោលបំណងធ្វើឲ្យមានភាពងាយស្រួលក្នុងការដំឡើងរបាយការណ៍ និងពង្រឹងគុណភាពនៃរបាយការណ៍ប្រចាំខែស្ដីពីអត្រាការប្រាក់មធ្យមថ្លឹងចំពោះប្រាក់បញ្ញើនិងឥណទាន។

### ២.១.២. ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន

ការដាក់ចេញប្រកាសស្ដីពី ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមតែរមិន ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ គឺជាការដាក់ចេញនូវក្របខណ្ឌគ្រប់គ្រងហានិភ័យឥណទានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដែលក្នុងនោះមានការបញ្ជាក់ពីការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធី ដែលមានអ៊ីមតែរមិនរបស់គ្រឹះស្ថាន។ ដើម្បីជួយសម្រួលដល់គ្រឹះស្ថាន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តនូវប្រកាសថ្មី ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសារាចរណែនាំស្ដីពី ការអនុវត្តប្រកាសស្ដីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន ដោយបញ្ជាក់បន្ថែមចំណុចមួយចំនួនដូចខាងក្រោម ៖

១/. អនុញ្ញាតអាចបន្តអនុវត្តតាមកាតព្វកិច្ចដូចការអនុវត្តកន្លងមក សម្រាប់ការបិទកិច្ចបញ្ជិកាគណនេយ្យឆ្នាំ២០១៧ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនដែលមិនទាន់មានលទ្ធភាពអនុវត្តបានតាមប្រកាសថ្មី។

២/. ការរៀបចំការពិនិត្យឡើងវិញ និងការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីទាំងអស់របស់គ្រឹះស្ថានដូចមានកំណត់ក្នុងប្រកាសលេខធ៧-០១៧-៣៤៤ ប្រ.ក ឲ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១៨។ លទ្ធផលនៃការត្រួតពិនិត្យឡើងវិញ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៣/. គ្រឹះស្ថានត្រូវរៀបចំការវាយតម្លៃឲ្យបានពេញលេញអំពីតម្រូវការសំវិធានធនលើអ៊ីមភែរមិនសម្រាប់ឆ្នាំ២០១៨ ស្របតាមបញ្ញត្តិនានាចាប់ពីប្រការ ៤៩ ដល់ប្រការ ៧១ និងត្រូវបង្ហាញឲ្យច្បាស់អំពីចំនួនសំវិធានធនលើអ៊ីមភែរមិនទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗ (Credit Risk Grading)។

៤/. គ្រឹះស្ថានត្រូវរៀបចំធ្វើបច្ចុប្បន្នកម្ម និងផ្ញើគោលនយោបាយ និងនីតិវិធីឥណទានស្របតាមប្រកាសជាធរមាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពីក្រុមប្រឹក្សាភិបាលបានអនុម័ត ចំពោះការធ្វើបច្ចុប្បន្នកម្មគោលនយោបាយ និងនីតិវិធីឥណទាន។

៥/. ការកត់ត្រាសំវិធានធនជាក់លាក់ និងការប្រាក់បង្គរ។

៦/. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវអនុវត្តតាមប្លង់គណនីឯកភាព (Uniform Chart of Accounts) ដូចគ្រឹះស្ថានធនាគារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ត្រូវអនុវត្តប្លង់គណនីឯកភាពដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

៧/. ការកំណត់ចំណាត់ថ្នាក់ និងសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី។

៨/. ការធ្វើសំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ។

### ២.១.៣. ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ដើម្បីពង្រឹងនូវភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប្រកាសនេះនឹងជួយពង្រឹងមូលដ្ឋានដើមទុនសម្រាប់បំពេញការខាតបង់នានា ដែលអាចកើតឡើងពីហានិភ័យរបស់គ្រឹះស្ថាន បង្ការការធ្លាក់ចុះនៃដើមទុនមិនឲ្យទាបជាងកម្រិតដើមទុនអប្បបរមា និងកាត់បន្ថយហានិភ័យដែលបណ្តាលមកពីទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុនិងវដ្តសេដ្ឋកិច្ច (Pro-cyclicality)។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប ត្រូវបានអនុវត្តដូចគ្នានឹងការគណនាគួបសរុបក្នុងរបាយការណ៍ស្តីពីអនុបាតសាធនភាព។

ទ្រនាប់ដើមទុនរួមមានទ្រនាប់ដើមទុនខនស៊ើវេសិន (Capital Conservation) និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital)។ ទ្រនាប់ដើមទុនខនស៊ើវេសិន សំដៅដល់ដើមទុនដែលគ្រឹះស្ថានត្រូវបង្កើតឡើងក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា ដើម្បីទប់ទល់នឹងការធ្លាក់ចុះនៃដើមទុននៅពេលមានការខាតបង់កើតឡើង។ ទ្រនាប់ដើមទុននេះបង្កើតឡើងតាមរយៈការបង្កើនដើមទុនថ្នាក់ទី១ ពោលគឺដើមទុនចុះបញ្ជី និង/ឬទុនបម្រុងដែលមិនអាចបែងចែកបាន។ គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវមានទ្រនាប់ដើមទុនខនស៊ើវេសិនយ៉ាងតិច ៥០% នៃទ្រនាប់ដើមទុនដែលបានកំណត់ ពោលគឺ ១,២៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ឲ្យបានមុនថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងត្រូវបំពេញឲ្យបានពេញលេញចំនួន ២,៥% មុនថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

ចំណែកទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ត្រូវបានរៀបចំឡើងដើម្បីធានាថាគ្រឹះស្ថានមានដើមទុនគ្រប់គ្រាន់សម្រាប់បំពេញការខាតបង់នានា នៅពេលធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថាឥណទានមានកំណើនលើសលុប ដែលអាចបណ្តាលឲ្យមានហានិភ័យជាប្រព័ន្ធ។ ធនាគារជាតិនៃកម្ពុជាអាចកំណត់ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ចាប់ពីកម្រិត ០% ទៅ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។ ទន្ទឹមនេះ ប្រកាសនេះក៏បានកំណត់លក្ខខណ្ឌដោយឡែកសម្រាប់គ្រឹះស្ថានធនាគារ ដែលមានកាតព្វកិច្ចអនុវត្តតាមប្រកាសស្តីពី ការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគតផងដែរ។

### ២.១.៤. ការអនុវត្តប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

យោងតាមសារាចរណែនាំស្តីពី "ការអនុវត្តប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ" នៅថ្ងៃ០៧ ខែមីនា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថា ស្ថានភាពហិរញ្ញវត្ថុនៅកម្ពុជាមានភាពរឹងមាំ និងកំណើនឥណទានសមស្របទៅបរិបទនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានកំណត់អនុបាតនៃទ្រនាប់ដើមទុនខោធើស៊ីឃ្លីខល (Countercyclical capital buffer) ចំនួន ០% រហូតដល់មានការជូនដំណឹងជាថ្មី។

### ២.១.៥. ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ

ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ សំដៅដល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលគ្រឹះស្ថានត្រូវធ្វើការតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការគ្រប់គ្រងប្រតិបត្តិការសន្ទនីយភាពប្រកបដោយសុវត្ថិភាព និងមានភាពរឹងមាំ។ ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍គោលនយោបាយរូបិយវត្ថុផង និងជាឧបករណ៍ម៉ាក្រូប្រុងប្រយ័ត្នផង ដែលអាចត្រូវបានផ្លាស់ប្តូរទៅតាមគោលដៅនៃការអនុវត្ត និងកាលៈទេសៈសេដ្ឋកិច្ចសកល។ ធនាគារពាណិជ្ជចាំបាច់ត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជាស្មើនឹង ៨% (ប្រាំបីភាគរយ) ចំពោះប្រាក់រៀល និង ១២,៥% (ដប់ពីរក្បៀស ប្រាំភាគរយ) ចំពោះរូបិយបណ្ណបរទេស។

## ២.២. សកម្មភាពនៃការត្រួតពិនិត្យ

ភាពរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ស្ថិរភាពប្រព័ន្ធធនាគារទាំងមូល។ អាស្រ័យហេតុនេះ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅតែជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារ។ ក្របខណ្ឌត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ និងធ្វើបច្ចុប្បន្នកម្មអនុលោមទៅតាមស្តង់ដារនិងឧត្តមានុវត្តភាពជាអន្តរជាតិ ក៏ដូចជា សមស្របទៅតាម

ការពង្រីកវិសាលភាពនៃប្រតិបត្តិការគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន។ ការត្រួតពិនិត្យដល់ទីកន្លែងនិងលើឯកសារ ការវិភាគនិងតាមដានម៉ាក្រូ ក៏ដូចជា ការរៀបចំបទប្បញ្ញត្តិនានាឲ្យទាន់ពេលវេលាស្របតាមការរីកចម្រើននៃប្រព័ន្ធធនាគារ ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាបាននូវប្រសិទ្ធភាព និងតម្លាភាពនៃប្រព័ន្ធធនាគារ។ ប្រព័ន្ធត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានអនុវត្តតាមការវាយតម្លៃប្រចាំគ្រា រួមមាន ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដោយផ្អែកលើវិធីសាស្រ្ត CAMELS និងការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដើម្បីរក្សានូវស្ថិរភាពហិរញ្ញវត្ថុនិងភាពរឹងមាំនៃប្រព័ន្ធធនាគារទាំងមូល ក្នុងការផ្តល់ទំនុកចិត្តដល់សាធារណជន។ ការអនុវត្តក្របខណ្ឌនៃការត្រួតពិនិត្យផ្អែកលើហានិភ័យនឹងនាំមកនូវការវិភាគកាន់តែមានប្រសិទ្ធភាពជាងមុន លើសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈការវាយតម្លៃលើសំណុំហានិភ័យ ស្ថានភាពហិរញ្ញវត្ថុ ដំណើរការគ្រប់គ្រងហានិភ័យ និងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជារួមបន្តរក្សាបាននូវស្ថានភាពល្អប្រសើរ ទាំងអភិបាលកិច្ច និងស្ថានភាពហិរញ្ញវត្ថុ។

### ២.៣. ការបញ្ចប់ប្រតិបត្តិការរបស់គ្រឹះស្ថានប្រតិស្រុតិ

ធនាគារជាតិនៃកម្ពុជានៅតែបន្តការដាក់ចេញបទប្បញ្ញត្តិ ការត្រួតពិនិត្យទាំងលើឯកសារ និងដល់ទីកន្លែងចំពោះគ្រឹះស្ថានប្រតិស្រុតជាប្រចាំ លើការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជា ក៏បានបង្កើន និងកំពុងតាមដានគ្រឹះស្ថានឆ្លៀតឱកាសមួយចំនួនដែលបាន និងកំពុងអូសទាញប្រជាពលរដ្ឋធ្វើការវិនិយោគមូលធនរបស់ខ្លួន តាមរយៈ ការកៀនប្រមូលប្រាក់បញ្ញើពីសាធារណជនក្រោមរូបភាព "កិច្ចសន្យាខ្ចីប្រាក់" ផ្តល់អត្រាការប្រាក់ខ្ពស់ និងការផ្តល់ការប្រាក់កម្ចីល្មើសច្បាប់។ ជាលទ្ធនៃការត្រួតពិនិត្យ និងការវាយតម្លៃ ធនាគារជាតិនៃកម្ពុជា បានសម្រេចបញ្ចប់ប្រតិបត្តិការគ្រឹះស្ថានប្រតិស្រុតិ រួមមាន ១/. ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១ ២/. គ្រឹះស្ថានឥណទានជនបទ ៣៣ និង ៣/. អាជីវករប្តូរប្រាក់ ៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥។

## ៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

### ៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

#### ៣.១.១. ស្តង់ដារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានតម្រូវឲ្យអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) នៅដើមឆ្នាំ២០១៩។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុង ១/. ធ្វើបច្ចុប្បន្នកម្មប្លង់គណនីឯកភាព ២/. កែសម្រួលទម្រង់របាយការណ៍ប្រចាំខែរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៣/. រៀបចំសេចក្តីណែនាំស្តីពីការរៀបចំប្លង់គណនីឯកភាព និងការបញ្ជូលរបាយការណ៍ ដើម្បីផ្ញើមកធនាគារជាតិនៃកម្ពុជា និង ៤/. សិក្សាលើផលប៉ះពាល់បទប្បញ្ញត្តិដទៃទៀត ដើម្បីចៀសវាងចំណុច

មិនស្របគ្នារវាងបទប្បញ្ញត្តិត្រួតពិនិត្យ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំកែសម្រួលប្រព័ន្ធរាយការណ៍របាយការណ៍ត្រួតពិនិត្យ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការងារត្រួតពិនិត្យ ពង្រឹងសុក្រឹតភាពនៃទិន្នន័យ និងរៀបចំអនុលោមភាពរបាយការណ៍ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងការត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ក៏ដូចជាស្របតាមការវិវឌ្ឍថ្មីៗនៃវិស័យធនាគារ។ នៅដំណាច់ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាក៏បានចេញសេចក្តីជូនដំណឹងថ្មីមួយ ស្តីពីសេចក្តីព្រាងប្លង់គណនីឯកភាពថ្មី ដែលបានធ្វើបច្ចុប្បន្នកម្មឲ្យស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងដើម្បីឲ្យគ្រឹះស្ថានត្រៀមខ្លួនអនុវត្តនាពេលខាងមុខដ៏ខ្លី។ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការធ្វើបច្ចុប្បន្នភាពលើប្លង់គណនីឯកភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរៀបចំសិក្ខាសាលាស្តីពីការអនុវត្តប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភែរមិន ២ លើករួចមកហើយ។

### ៣.១.២ ការិយាល័យព័ត៌មានឥណទានកម្ពុជា

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី មានទ្រព្យសកម្មសរុបប្រមាណ ៤៥,៩ ប៊ីលានរៀល និងមានគ្រឹះស្ថានជាសមាជិកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១៥៧ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានធនាគារពាណិជ្ជ ៤៣ គ្រឹះស្ថានធនាគារឯកទេស ១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧១ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៣ និងគ្រឹះស្ថានឥណទានជនបទ ១០។

រូបភាព១២ ៖ សំពៀតឥណទាន និងចំនួនគណនីអតិថិជនរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**រូបភាព១៣ ៖ ការពិនិត្យរបាយការណ៍ឥណទាន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ការបញ្ចូលព័ត៌មានឥណទានឯកត្តជនរបស់សមាជិកនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានមាន ២.៩៦៨.៩៤២ គណនី ស្មើនឹង ៨៤,៣ ទ្រីលានរៀល។ ទន្ទឹមនេះ ការចូលប្រើប្រាស់របាយការណ៍ឥណទានរបស់សមាជិកសរុប ៤.៧៤០.៥៧៥ ប្រតិបត្តិការ ក្នុងឆ្នាំ២០១៨ ដោយក្នុងនោះសមាជិកជាគ្រឹះស្ថានធនាគារមាន ២៦,៨% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧១,១% ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១,៧% និងគ្រឹះស្ថានឥណទានជនបទ ០,៤%។ ដើម្បីពង្រឹងគុណភាពនិងតម្លាភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ធនាគារជាតិនៃកម្ពុជា បន្តត្រួតពិនិត្យនិងវាយតម្លៃលើរបាយការណ៍ប្រចាំគ្រារបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ និងបានចេញលិខិតអញ្ជើញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ១៣ ដើម្បីពិភាក្សាអំពីការពង្រឹងការអនុវត្តតាមប្រកាសស្តីពី "ការចែករំលែកព័ត៌មានឥណទាន"។ ដោយឡែកធនាគារជាតិនៃកម្ពុជាក៏បានអនុញ្ញាតឲ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ប្រមូលទិន្នន័យឥណទានក្រុមហ៊ុនពីសមាជិកដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្រុមហ៊ុន។ ការអភិវឌ្ឍប្រព័ន្ធនេះមាន ៤ ជំហានសំខាន់ៗ រួមមាន ១/. ការអភិវឌ្ឍប្រព័ន្ធបញ្ចូលទិន្នន័យ ២/. ការអភិវឌ្ឍប្រព័ន្ធផ្នែករបាយការណ៍ឥណទាន ៣/. ការអភិវឌ្ឍប្រព័ន្ធប្រតិបត្តិការ និង ៤/. ការសាកល្បងប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្រុមហ៊ុន។ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ គ្រោងនឹងដាក់ឲ្យដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្រុមហ៊ុនជាផ្លូវការនៅដើមឆ្នាំ២០១៩។

### ៣.១.៣. ប្រតិបត្តិការប្រព័ន្ធទូទាត់

ប្រព័ន្ធទូទាត់នៅកម្ពុជាមានការវិវឌ្ឍគួរឲ្យកត់សម្គាល់ និងបានជំរុញឲ្យសេវាទូទាត់សងប្រាក់មានកំណើនខ្លាំង។ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យដំណើរការជាផ្លូវការប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment System) ដែលកំពុងប្រតិបត្តិដោយគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤២ ហើយក្នុងនោះគ្រឹះស្ថាន ៧ បានដាក់ដំណើរការសេវានេះតាមរយៈ

ប្រតិបត្តិការធនាគារចល័ត។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឲ្យដំណើរការបឋមចំពោះប្រព័ន្ធខេមបូឌានស៊ែស្វិច (Cambodian Shared Switch) ដោយមានគ្រឹះស្ថាន ៥ *(ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារស្ថាបនា ភីអិលស៊ី ធនាគារប្រៃសណីយ៍កម្ពុជា ម.ក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ម.ក និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់)* កាលពីខែឧសភា ឆ្នាំ២០១៨។

ម្យ៉ាងទៀត ប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធអេឡិចត្រូនិកក៏មានការកើនឡើងយ៉ាងឆាប់រហ័សផងដែរ ដោយសារការវិវឌ្ឍយ៉ាងលឿននៃបច្ចេកវិទ្យា។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២៥ ក៏បានផ្តល់សេវា Internet Banking និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២០ បានផ្តល់សេវាធនាគារចល័តដល់អតិថិជន។ ទំហំប្រតិបត្តិការទូទាត់ធ្វើឡើងតាម Internet Banking សរុប ១.០៣២.៦៧៤ ប្រតិបត្តិការ គិតជាទឹកប្រាក់ស្មើ ២០,២ ទ្រីលានរៀល ចំណែកឯប្រតិបត្តិការធនាគារចល័តមាន ១៩.០៧៤.៩៨៣ គិតជាទឹកប្រាក់ស្មើ ២៧,៧ ទ្រីលានរៀល។

គិតត្រឹមដំណាច់ឆ្នាំ២០១៨ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៤ និងគ្រឹះស្ថានធនាគារ ៥ បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់សេវាទូទាត់ ដែលមានដូចជា សេវាផ្ទេរប្រាក់ ដកប្រាក់ ដាក់ប្រាក់ ទូទាត់វិក្កយបត្រ ទូទាត់តម្លៃរាយ ទូទាត់អនឡាញ និងផ្ទេរប្រាក់ឆ្លងព្រំដែន។ ទន្ទឹមនេះ ក្រុមហ៊ុន ៥ ទទួលបានការអនុញ្ញាតឲ្យដំណើរការជាអ្នកដំណើរការតតិយភាគីក្នុងការផ្តល់សេវាផ្ទេរប្រាក់ឆ្លងព្រំដែន។ ភ្នាក់ងាររបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នៅទូទាំងប្រទេសសរុបមាន ២៤.១៦៤ ដែលបានធ្វើប្រតិបត្តិការទូទាត់សងប្រាក់សរុបមាន ៥១.៨០០.២៦៩ គិតជាទឹកប្រាក់ ២៧,៧ ទ្រីលានរៀល។

ដោយឡែក ចំនួនប្រតិបត្តិការទូទាត់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមាន ៩២.៩២៤.៦៥១ គិតជាទឹកប្រាក់ ៦២,៧ ទ្រីលានរៀល ហើយចំនួនភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់សរុបមាន ១០.២៨៥ នៅទូទាំងប្រទេស។ ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបមាន ៧៩០.០០០ ស្មើនឹងទឹកប្រាក់សរុប ២,០ ទ្រីលានរៀល។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៣៧ បានផ្តល់សេវាផ្ទេរប្រាក់តាមរយៈប្រព័ន្ធស្វីស (SWIFT) ដែលមានប្រតិបត្តិការសរុប ៨៩៨.៣៧៥ គិតជាទឹកប្រាក់ ១៨៦,៨ ទ្រីលានរៀល។

### ប្រអប់១ ៖ សេចក្តីណែនាំស្តីពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា

បច្ចុប្បន្ន វិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ត្រូវបានពង្រីកយ៉ាងទូលំទូលាយ ដែលចំនួនអ្នកប្រើប្រាស់បណ្តាញទូរគមនាគមន៍ (ទូរស័ព្ទនិងអ៊ីនធឺណិត) កាន់តែមានការកើនឡើងគួរឲ្យកត់សម្គាល់។ ទន្ទឹមនោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បាននិងកំពុងប្រកួតប្រជែងគ្នាក្នុងការបង្កើតសេវាហិរញ្ញវត្ថុឌីជីថលសម្រាប់អ្នកប្រើប្រាស់ តាមរយៈបច្ចេកវិទ្យានិងបណ្តាញទូរគមនាគមន៍។ ជាក់ស្តែង គ្រឹះស្ថានកាន់តែច្រើនបានដាក់ឲ្យប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល និង

ប្រតិបត្តិការទូទាត់ឆ្លងប្រទេស ព្រមទាំងបានចូលជាសមាជិកប្រព័ន្ធទូទាត់រហ័ស (Fast Payment System) ប្រព័ន្ធខេមបូឌានស៊ែស្វិច (Cambodian Shared Switch) និងប្រើប្រាស់ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ដែលបានធ្វើឲ្យប្រតិបត្តិការអន្តរធនាគារកាន់តែមានភាពប្រទាក់ក្រឡាជាងមុន។ ទន្ទឹមនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលមានការកើនឡើងគួរឲ្យកត់សម្គាល់ ធនាគារជាតិនៃកម្ពុជាក៏សង្កេតឃើញពីភាពងាយទទួលរងការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យានៅក្នុងវិស័យនេះ ដែលបានកើតឡើងជាសកល ក្រោមរូបភាពដូចជា ការចូលលួចទិន្នន័យ ការចូលទៅគ្រប់គ្រងគណនី ការក្លែងបន្លំប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ ការជំរិតទារប្រាក់ជាថ្នូរនឹងការរក្សាទុកទិន្នន័យមិនឲ្យបាត់បង់ និងហិរញ្ញប្បទានភេរវកម្ម ជាដើម។

ដោយយល់ឃើញពីហានិភ័យទាំងអស់នេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលបំណងរក្សាព័ត៌មានសម្ងាត់របស់អតិថិជន ការពារសុវត្ថិភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ ពង្រឹងសមត្ថភាពគ្រឹះស្ថានក្នុងការទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងពង្រឹងនិរន្តរភាពអាជីវកម្មរបស់គ្រឹះស្ថាន ដើម្បីឈានទៅធានាសុវត្ថិភាពប្រព័ន្ធធនាគារទាំងមូល ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ កិច្ចការទាំងអស់នេះអាចសម្រេចទៅបាន លុះត្រាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការយកចិត្តទុកដាក់បន្ថែមលើអភិបាលកិច្ច និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ព្រមទាំងការធ្វើសវនកម្មលើមុខងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ៣.២. ការអនុវត្តការងារបរិយាប័ន្នហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបានបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ទាំងថ្នាក់ខេត្តនិងស្រុក ៤ លើក ដែលមានអ្នកចូលរួមសរុប ១.៧៥៤ នាក់ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដល់អាជ្ញាធរដែនដី ប្រជាពលរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ អំពី ១/. សារៈសំខាន់និងផលប្រយោជន៍នៃវិស័យមីក្រូហិរញ្ញវត្ថុ ២/. តួនាទី-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ៣/. កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និង ៤/. ការយល់ដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ។

ក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ រួមមាន អង្គការ UNCDF ធនាគារពិភពលោក សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងអង្គការ Good Return។ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាស្ថាប័នដឹកនាំ រួមជាមួយក្រសួង-ស្ថាប័នដែលជាសមាជិកក្រុមការងារ ក៏បាននិងកំពុងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពី បរិយាប័ន្នហិរញ្ញវត្ថុក្រោមកិច្ចសហការជាមួយអង្គការ UNCDF។ យុទ្ធសាស្ត្រជាតិនេះ មានគោលបំណងបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបាន

សេវាហិរញ្ញវត្ថុ ៥០% (ពី ២៧% មក ១៣%) និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ចតាមរយៈសកម្មភាពអាទិភាពដូចជា ១/. លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ២/. ជំរុញនវានុវត្តន៍ផលិតផលឥណទានសម្រាប់សហគ្រាសធុនតូចបំផុត តូច និងមធ្យម ៣/. ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់ ៤/. ផ្តល់អាទិភាពដល់ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងឲ្យដំណើរការបានល្អប្រសើរ ៥/. ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង ៦/. លើកកម្ពស់សិទ្ធិអតិថិជននិងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

ទន្ទឹមនេះ ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សង្គម និងសេដ្ឋកិច្ចជាតិទាំងមូល។ ក្នុងវិស័យហិរញ្ញវត្ថុ ស្ត្រីត្រូវបានចាត់ទុកថាជាអតិថិជនដែលមានការទទួលខុសត្រូវខ្ពស់។ ដោយពិនិត្យឃើញពីតួនាទីសំខាន់ទាំងនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងផ្តួចផ្តើមគម្រោងថ្មីៗ ដើម្បីលើកកម្ពស់ការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការរបស់ស្ត្រី។ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាសមាជិកពេញអង្គ និងជាសមាជិកគណៈកម្មាធិការយ៉េនឌ័រ និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីរបស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) បានប្តេជ្ញាអនុវត្តផែនការសកម្មភាពនៃសេចក្តីប្រកាស Denarau តាមរយៈការជំរុញស្ត្រីក្នុងភាពជាអ្នកដឹកនាំ ទាំងក្នុងស្ថាប័នផ្ទាល់ និងតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលបំណងបង្កើនសំឡេងស្ត្រីក្នុងការបង្កើតគោលនយោបាយផ្នែកហិរញ្ញវត្ថុ ដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អតិថិជនជាស្ត្រី។

### ប្រអប់២ ៖ បច្ចេកវិទ្យាហិរញ្ញវត្ថុ ( Financial Technology )

វាក្យសព្ទ "បច្ចេកវិទ្យាហិរញ្ញវត្ថុ" ឬ financial technology ហៅកាត់ថា Fintech សំដៅទៅលើនវានុវត្តដែលជំរុញដោយបច្ចេកវិទ្យា កើតមានឡើងនៅក្នុងការផ្តល់សេវាហិរញ្ញវត្ថុ។ ផ្នែកសំខាន់ៗនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមមាន ការវិភាគសំណុំទិន្នន័យធំៗ (Big data analysis) តិចនិកនៃការវិភាគ ការជួញដូរដោយស្វ័យប្រវត្តិ ការផ្តល់ការប្រឹក្សាដោយស្វ័យប្រវត្តិ និងការរក្សាទុកកំណត់ត្រាហិរញ្ញវត្ថុ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុបានទាក់ទាញចំណាប់អារម្មណ៍របស់ពិភពលោក ដោយផ្តល់នូវជម្រើសជាច្រើននៃការទូទាត់ បើធៀបនឹងមធ្យោបាយទូទាត់ដែលមានលក្ខណៈបែបប្រពៃណី។ បច្ចេកវិទ្យាហិរញ្ញវត្ថុបានផ្តល់គុណសម្បត្តិច្រើន តាមរយៈការជំរុញឲ្យសេវាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ចំណាយតិច ឆាប់រហ័ស សមាហរណកម្មខ្ពស់ លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ច។ ជាក់ស្តែង ប្រព័ន្ធទូទាត់តាមទូរស័ព្ទដៃក្នុងប្រទេសចិននិងកេនយ៉ា បានជួយឲ្យប្រជាជនរាប់លាននាក់ដែលមិនមានគណនីនៅធនាគារ (unbanked people) ចូលទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដោយប្រជាជនទទួលបានសេវាហិរញ្ញវត្ថុឆាប់រហ័សនិងចំណាយប្រតិបត្តិការទាប។ ទន្ទឹមនឹងនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុក៏បានភ្ជាប់មកជាមួយនូវហានិភ័យផងដែរ ដែលចាំបាច់ត្រូវតែមានការយល់ដឹងស៊ីជម្រៅនិងយន្តការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ក្នុងកិច្ចការពារអតិថិជននិងវិនិយោគិន ប្រឆាំងនឹងការក្លែងបន្លំ ការគេច

ពន្ធ ការលាងលុយកខ្វក់និងហិរញ្ញប្បទានភេរវកម្ម ពិសេសការពារនូវសុចរិតភាពនិងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ដូច្នេះ ការអភិវឌ្ឍក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិផ្អែកលើទស្សនៈអនាគតត្រូវរៀបចំឡើងរួមផ្សំនឹងគំនិតច្នៃប្រឌិត ភាពទន់ភ្លន់ និងជំនាញច្បាស់លាស់ ដោយមិនធ្វើឲ្យប៉ះពាល់ដល់នវានុវត្តភាព។

ដោយឡែក ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គឺស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ។ ធនាគារជាតិនៃកម្ពុជាបានបង្កលក្ខណៈអំណោយផលដល់ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យធនាគារ ដូចជា ការអនុញ្ញាតឲ្យប្រើទូរស័ព្ទដៃ ប្រព័ន្ធ QR Code និងគណនី e-wallet សម្រាប់ទូទាត់និងផ្ទេរប្រាក់ ទាំងក្នុងប្រទេសនិងឆ្លងដែន។ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទូទាត់រាយនៅឆ្នាំ២០១២ សម្រាប់ផាត់ទាត់មូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទាន។ ប្រព័ន្ធសម្រាប់ទូទាត់រហ័ស (FAST Payment System) បានដាក់ឲ្យដំណើរការនៅឆ្នាំ២០១៦ សម្រាប់សម្រួលដល់ការទូទាត់ភ្លាមៗនូវការផ្ទេរមូលនិធិ។ ប្រព័ន្ធ Cambodian Shared Switch (CSS) ត្រូវបានដាក់ឲ្យដំណើរការនៅខែតុលា ឆ្នាំ២០១៧ សម្រាប់សម្រួលដល់ប្រតិបត្តិការម៉ាស៊ីន ATM និង POS។ ជាមួយគ្នានេះ ក្របខណ្ឌបទប្បញ្ញត្តិនានាសំដៅលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុកំពុងត្រូវបានរៀបចំជាបន្តបន្ទាប់ ទន្ទឹមគ្នានឹងការបន្តអភិវឌ្ឍសមត្ថភាពជំនាញរបស់មន្ត្រីធនាគារជាតិនៃកម្ពុជាលើផ្នែកច្បាប់និងបទប្បញ្ញត្តិ ដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។

## ៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

ធនាគារជាតិនៃកម្ពុជាផ្តោតការយកចិត្តទុកដាក់ខ្ពស់ ចំពោះការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាពិសេសកំពុងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួង ចាប់ពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តគម្រោងជាច្រើនដូចជា យុទ្ធនាការ "តោះ! និយាយពីលុយ" សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ" ការចុះផ្សព្វផ្សាយផ្ទាល់តាមមូលដ្ឋាន និងបានដាក់ឲ្យប្រើប្រាស់សាកល្បងកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុតាមទូរស័ព្ទចល័តមានឈ្មោះថា "NBC-Edu" ដែលអាចទាញយកបានតាមរយៈ Google Play និង Apple App Store។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយអង្គការ Good Return ក្រុមហ៊ុន Viamo និងក្រុមហ៊ុនសែលកាត ក្នុងការដាក់ឲ្យដំណើរការសេវា ៣-២-១ ដែលជាសេវាផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុតាមរយៈទូរស័ព្ទចល័ត លើប្រធានបទដូចជា ១/. ការសន្សំនិងអត្ថប្រយោជន៍នៃការសន្សំ ២/. ការប្រើប្រាស់ឥណទាននិងការគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព និង ៣/. ការការពារបំណុលវ័ណ្ឌក។ សេវាកម្ម ៣-២-១ នេះ គឺជាសេវាផ្តល់ព័ត៌មានជាសំឡេង ដោយប្រជាជនកម្ពុជាអាចទទួលបានដំបូន្មានផ្នែកហិរញ្ញវត្ថុដោយគ្រាន់តែហៅទៅកាន់លេខ "៣-២-១" តាមរយៈទូរស័ព្ទចល័តនៅក្នុងប្រទេស។

ក្នុងគោលបំណងផ្តល់ព័ត៌មាន ការពារសិទ្ធិ ការពារផលប្រយោជន៍របស់អតិថិជន ព្រមទាំងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងលើការអនុវត្តប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការទទួលនិងដោះស្រាយបណ្តឹងអតិថិជនជាបន្តបន្ទាប់។ ជាមួយនេះ ក្រុមការងារគាំពារអតិថិជនបន្តទទួលនិងដោះស្រាយការតវ៉ា និង/ឬបណ្តឹងតាមរយៈប្រព័ន្ធទូរស័ព្ទ Hotline ទាំង ៥ ខ្សែ សម្រាប់ទីស្នាក់ការកណ្តាល និង ២១ ខ្សែទៀតនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។ ក្រុមការងារ Hotline បានទទួលបណ្តឹង ២៧៦ ករណី ដែលបណ្តឹងភាគច្រើនពាក់ព័ន្ធនឹងការបង់ផ្តាច់ឥណទានមុនកាលកំណត់ បញ្ហាស្នើសុំដកវត្ថុបញ្ចាំ ការគណនាការប្រាក់ ការខ្ចីចងការប្រាក់ក្រៅប្រព័ន្ធធនាគារ ការបង់ពិន័យផ្សេងៗ និងការសាកសួរព័ត៌មានផ្សេងៗ។

ក្នុងកំឡុងឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានកត់សម្គាល់ឃើញនូវសកម្មភាពផ្សព្វផ្សាយជាសាធារណៈយ៉ាងច្រើន តាមរយៈបណ្តាញសង្គម ខិត្តប័ណ្ណ និងសារតាមទូរស័ព្ទ ជាដើម ទាក់ទងនឹងការផ្តល់កម្ចីងាយៗនិងឆាប់រហ័ស។ សកម្មភាពផ្តល់កម្ចីទាំងនេះត្រូវបានពិនិត្យឃើញថា មិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ និងអាចបង្កជាហានិភ័យមួយចំនួនដល់អ្នកដែលប្រើប្រាស់ ដូចជា ១/. ការប្រឈមមុខនឹងបំណុលវ័ណ្ឌក ដោយសារអត្រាការប្រាក់និងកម្រៃសេវាផ្សេងៗខ្ពស់យ៉ាងខ្លាំងជាងគ្រឹះស្ថានដែលស្របច្បាប់ និងការគណនាការប្រាក់បែបកេងចំណេញពីអ្នកខ្ចីប្រាក់ ២/. ការប្រឈមមុខនឹងការគំរាមកំហែង គាបសង្កត់ ក្រោមរូបភាពផ្សេងៗ ដើម្បីបង្ខំឲ្យសងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យដែលមិនសមហេតុផលទៅក្រុមហ៊ុនវិញ និង ៣/. ទ្រព្យធានារបស់អតិថិជនអាចត្រូវបានក្រុមហ៊ុនឬអ្នកផ្តល់កម្ចីខុសច្បាប់រឹបអូស ដោយពុំឆ្លងកាត់ការសម្រេចពីតុលាការ ជាដើម។ ដើម្បីការពារសាធារណជនពីផលវិបាកទាំងនេះ ធនាគារជាតិនៃកម្ពុជាបានចេញនូវសេចក្តីប្រកាសព័ត៌មាន ក្រើនរំលឹកដល់ប្រជាពលរដ្ឋឲ្យបង្កើនការប្រុងប្រយ័ត្ន និងជៀសវាងការប្រើប្រាស់សេវាកម្មកម្ចីពីក្រុមហ៊ុនឬអ្នកផ្តល់កម្ចីដែលគ្មានច្បាប់អនុញ្ញាត និងកំពុងស្នើសុំការសហការពីអាជ្ញាធរពាក់ព័ន្ធដើម្បីចាត់វិធានការតាមផ្លូវច្បាប់ទៅលើក្រុមហ៊ុន ឬអ្នកផ្តល់កម្ចីខុសច្បាប់តាមគ្រប់រូបភាពទាំងអស់។

ក្នុងខណៈដែលការប្រើប្រាស់កាសអេឡិចត្រូនិក មិនត្រូវបានអនុញ្ញាតនៅបណ្តាប្រទេសជាច្រើន សម្រាប់កម្ពុជាថ្មីៗនេះ ក៏មានការផ្សព្វផ្សាយ ចរាចរ ទិញ លក់ ដូរ និងទូទាត់កាសអេឡិចត្រូនិកមួយចំនួន ដូចជា KH Coin, Suncoin, K coin, One-coin, Forex coin និងកាសអេឡិចត្រូនិកប្រហាក់ប្រហែលផ្សេងទៀតដោយគ្មានច្បាប់អនុញ្ញាត ដែលអាចបង្កហានិភ័យដល់សាធារណជននិងសង្គមទាំងមូល រួមមាន ១/. ការចេញផ្សាយដោយពុំមានវត្ថុធានាសងត្រឡប់មកវិញ ២/. ការទទួលរងការខាតបង់លើការវិនិយោគ ដោយសារតែតម្លៃចារីករបស់កាសអេឡិចត្រូនិកប្រែប្រួលគ្មានមូលដ្ឋានច្បាស់លាស់ ៣/. ការប្រឈមនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងធ្វើឲ្យបាត់បង់មូលនិធិដោយសារការលួចចូលទៅក្នុងប្រព័ន្ធ និង ៤/. កង្វះយន្តការការពារផលប្រយោជន៍អតិថិជន អ្នកប្រើប្រាស់កាសអេឡិចត្រូនិកជាជនអនាមិក ពុំមានការសម្គាល់អត្តសញ្ញាណ ឬ សាវតារបស់អ្នកប្រើប្រាស់បាន

ច្បាស់លាស់ ដែលជាហានិភ័យក្នុងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ អាជ្ញាធរមានសមត្ថកិច្ចរួមមាន ពីធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួមអំពាវនាវដល់សាធារណជន ឲ្យប្រុងប្រយ័ត្នចំពោះការឃោសនាផ្សព្វផ្សាយ កៀរគរប្រមូលមូលនិធិ និងការធ្វើប្រតិបត្តិការទិញ លក់ ដូរញដូរ ទូទាត់ កាសអេឡិចត្រូនិក ដែលមិនមានអាជ្ញាបណ្ណត្រឹមត្រូវ និងផ្តន្ទាទោសតាមផ្លូវច្បាប់ជាធរមានចំពោះបុគ្គល ឬនីតិបុគ្គលណាដែលធ្វើសកម្មភាពទាំងនេះ ហើយជាលទ្ធផល អាជ្ញាធរមានសមត្ថកិច្ចក៏បានចាត់វិធានការចុះត្រួតពិនិត្យនិងបញ្ឈប់សកម្មភាពដល់ក្រុមហ៊ុនមួយចំនួនផងដែរ។

## ៣.៤. ប្រតិបត្តិការទីផ្សារអន្តរធនាគារ

ប្រតិបត្តិការទីផ្សារអន្តរធនាគារនិវាសជនតាមប្រភេទគ្រឹះស្ថាន ប្រមាណ ៥៤,៦% ត្រូវបានធ្វើឡើងជាមួយធនាគារជាតិនៃកម្ពុជា ៣២,២% ជាមួយគ្រឹះស្ថានធនាគារ ១០,៣% ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ២,៥% ជាមួយក្រុមហ៊ុនធានារ៉ាប់រង និង ០,៥% ជាមួយក្រុមហ៊ុនមូលបត្រ។ ទន្ទឹមនេះ ៥៤,៦% ជាប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ៣២,៦% ជាប្រភេទប្រាក់បញ្ញើ ៧,១% ជាកម្ចីមូលនិធិ ៣,២% ជាកម្ចីអន្តរធនាគារ ២,៣% ជាការវិនិយោគក្នុងទីផ្សាររូបិយប័ណ្ណ និង ០,៣% ជាធាតុនៅក្នុងតារាងក្រៅតុល្យការ។

រូបភាព១៤ ៖ ប្រតិបត្តិការទីផ្សារអន្តរធនាគារ-និវាសជន







ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ដោយឡែក ប្រតិបត្តិការទីផ្សារអន្តរធនាគារអនិវាសជនត្រូវបានធ្វើឡើងតែ ៣ គ្រឹះស្ថាន ប៉ុណ្ណោះ រួមមាន ជាមួយគ្រឹះស្ថានធនាគារមានប្រមាណ ៨៨,៨% ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតប្រមាណ ១០,៥% និងជាមួយក្រុមហ៊ុនមូលបត្រប្រមាណ ០,៧%។ ប្រតិបត្តិការជិតពាក់កណ្តាល គឺជាកម្ចីមូលនិធិ (៤៤,៨%) ជាប្រភេទប្រាក់បញ្ញើ (៤៣,៥%) និងការវិនិយោគក្នុងទីផ្សាររូបិយប័ណ្ណ (១១,៦%)។

**រូបភាព១៥ ៖ ប្រតិបត្តិការទីផ្សារអន្តរធនាគារ-អនិវាសជន**







ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣.៥. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ

ទីផ្សារអចលនវត្ថុកម្ពុជានៅតែមានសកម្មភាពគួរឲ្យកត់សម្គាល់ ស្របគ្នាទៅនឹងកំណើនសេដ្ឋកិច្ចកម្ពុជា និងភាពប្រសើរឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ គិតត្រឹមដំណាច់ឆ្នាំ ២០១៨ ផលធៀបឆ្នាំលើឆ្នាំនៃកំណើនឥណទានធនាគារនិងមីក្រូហិរញ្ញវត្ថុចំពោះវិស័យអចលនទ្រព្យមានកម្រិត ៣៦,៥% និង ៣៣,៩% រៀងគ្នា។ ឥណទានរបស់ប្រព័ន្ធធនាគារចំពោះវិស័យអចលនទ្រព្យមានកម្រិត ២៦,៦% នៃសំពៀតឥណទានសរុប ក្នុងនោះកម្រិតឥណទានចំពោះវិស័យអចលនទ្រព្យ ៩៦% ត្រូវបានផ្តល់ដោយគ្រឹះស្ថានធនាគារ និង ៤% ត្រូវបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ឥណទានចំពោះវិស័យអចលនទ្រព្យ រួមមាន សកម្មភាពអចលនទ្រព្យ ការសាងសង់ និងការទិញផ្ទះសម្រាប់លំនៅដ្ឋាន។ ថ្វីត្បិតតែចំណែកទីផ្សារឥណទានចំពោះវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានទំហំតូចខ្លាំងបើធៀបទៅនឹងធនាគារក៏ដោយ ប៉ុន្តែកំណើនឥណទានដ៏ខ្ពស់ចំពោះវិស័យនេះ ទាមទារឲ្យមានការត្រួតពិនិត្យជាប្រចាំលើប្រតិបត្តិការរបស់គ្រឹះស្ថានដែលពាក់ព័ន្ធ។

**រូបភាព១៦ ៖ ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

តាមរយៈទិន្នន័យក្នុងប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) បានបង្ហាញថា លំហូរទុនវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យ (រួមបញ្ចូលនូវគ្រប់ប្រភេទអចលនទ្រព្យនិងខុនដូ) របស់កម្ពុជាក្នុងឆ្នាំ២០១៨ មាន ១.៤៧៤ ប៊ីលានរៀល រួមមានប្រទេសចិន ៥៨,៨% ប្រទេសសិង្ហបុរី ២៨,៣% និងប្រទេសផ្សេងៗទៀតមាន ១២,៩% នៃការវិនិយោគសរុប។

**តារាង៧ ៖ លំហូរវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា[1]** (គិតជាប៊ីលានរៀល)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ការវិនិយោគជាដើមទុននៅកម្ពុជា | ៧.៤៨១ | ៧.៤០២ | ១០.០៤១ | ១១.២៨៤ | ១២.៥៥០ |
| ការវិនិយោគក្នុងវិស័យអចលនទ្រព្យ | ១.៧៨១ | ១.៥៣៩ | ១.២៦៨ | ១.៤៨៩ | ១.៤៧៤ |

ប្រភព ៖ ការប៉ាន់ស្មានក្នុងប្រព័ន្ធ ITRS (International Transaction Reporting System) របស់ធនាគារជាតិនៃកម្ពុជា

**រូបភាព១៧ ៖ លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា[2]**




ប្រភព ៖ ប្រព័ន្ធ ITRS របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់និងតាមដានវឌ្ឍនភាពវិស័យអចលនទ្រព្យជាប្រចាំ ជាពិសេសការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំពោះវិស័យអចលនទ្រព្យដែលជាវិស័យមានហានិភ័យខ្ពស់។ ក្នុងគោលដៅលើកកម្ពស់ការតាមដាន និងវិភាគពីវឌ្ឍនភាពវិស័យអចលនទ្រព្យ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តប្រមូលព័ត៌មានផ្សេងៗពាក់ព័ន្ធដើម្បីបង្កើតឲ្យមានសូចនាករសន្ទស្សន៍ថ្លៃអចលនវត្ថុ (Property Price Index) ដែលលទ្ធផលនៃការបង្កើតសន្ទស្សន៍នេះ នឹងផ្តល់ដល់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យ។

[1] *ទិន្នន័យលំហូរវិនិយោគចាប់ពីឆ្នាំ២០១៤ ត្រូវបានកែសម្រួលដោយប្រើប្រាស់វិធីសាស្ត្រ និងធាតុចូលថ្មី*

**រូបភាព១៨ ៖ ឥណទានទៅវិស័យអចលនទ្រព្យ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

វិស័យសំណង់បន្តមានកំណើនរឹងមាំ និងរួមចំណែកប្រមាណ ១/៥ នៅក្នុងកំណើនសេដ្ឋកិច្ច។ វឌ្ឍនភាពក្នុងវិស័យនេះក៏បានឆ្លុះបញ្ចាំងផងដែរតាមរយៈសូចនាករសំខាន់ៗ មានដូចជា ការកើនឡើងការនាំចូលសម្ភារសំណង់ (១៥%) និងផ្ទៃក្រឡាសំណង់សរុប (៨%)។ ចំនួនគម្រោងវិនិយោគក្នុងវិស័យសំណង់បានថយចុះ ៦% រីឯតម្លៃគម្រោងវិនិយោគបានធ្លាក់ចុះ ២០%។ គម្រោងវិនិយោគប្រមាណ ៥/៦ ជាសំណង់លំនៅដ្ឋាន ហើយវិនិយោគិនបរទេសភាគច្រើនមកពីប្រទេសចិន កូរ៉េ ជប៉ុន ថៃ តៃវ៉ាន់ សិង្ហបុរី និងអង់គ្លេស។ ជាមួយគ្នានេះ វិស័យសំណង់បានផ្តល់ឱកាសការងារឲ្យអ្នកជំនាញ និងកម្មករប្រមាណ ២២០.០០០ នាក់ ដែលធ្វើការតាមការដ្ឋានសំណង់ទូទាំងប្រទេស។

## ៣.៦. យន្តការការពារអ្នកដាក់ប្រាក់បញ្ញើ

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ បានកំណត់តួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាស្ថាប័នដឹកនាំការសិក្សាអំពីលទ្ធភាពបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើសម្រាប់គោលដៅរយៈពេលខ្លី ឆ្នាំ២០១៦-២០១៩។ ដើម្បីអនុវត្តផែនការសកម្មភាពនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារអនុវត្តគម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ដោយមានមុខងារនិងភារកិច្ចចម្បងៗ គឺ ១/. សិក្សា ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការការពារប្រាក់បញ្ញើនិងក្របខណ្ឌដំណោះស្រាយ ២/. សហការជាមួយភាគីពាក់ព័ន្ធនានាដើម្បីអនុវត្តគម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ និង ៣/. រាយការណ៍ជូនថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាអំពីវឌ្ឍនភាពនៃការអនុវត្តគម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងបន្តអនុវត្តគម្រោងនេះដោយផ្តោតសំខាន់លើការងារចំនួន ២ គឺ ការបង្កើតក្របខណ្ឌបទប្បញ្ញត្តិ និងការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធ។ បន្ទាប់ពីបានចូលជាសមាជិកមិនពេញសិទ្ធិ (Associate) របស់សមាគមធានារ៉ាប់រងប្រាក់បញ្ញើអន្តរជាតិ International Association of Deposit Insurers (IADI) ធនាគារជាតិនៃកម្ពុជាកំពុងរៀនសូត្របទពិសោធន៍ពីស្ថាប័នជាសមាជិក និងស្វែងយល់ពីនិន្នាការថ្មីៗនៃប្រព័ន្ធ

ការពារប្រាក់បញ្ញើជុំវិញពិភពលោក ដែលជាធាតុចូលដ៏សំខាន់សម្រាប់កម្ពុជាក្នុងការអភិវឌ្ឍប្រព័ន្ធការពារប្រាក់បញ្ញើប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងទទួលយកជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដែលមានវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) និងមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការកំណត់អត្រាបុព្វលាភ និងផ្តល់យោបល់ចំពោះការបង្កើតក្របខណ្ឌបទប្បញ្ញត្តិ ស្ថាប័នទទួលបន្ទុកអនុវត្តប្រព័ន្ធការពារប្រាក់បញ្ញើ និងក្របខណ្ឌដំណោះស្រាយពិសេស។

## ៤. ការកសាងសមត្ថភាពត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៤.១.ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តផ្តល់ឱកាសដល់មន្ត្រីត្រួតពិនិត្យក្នុងការចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗនៅតាមបណ្តាប្រទេសតំបន់អាស៊ី រួមមាន ជប៉ុន ហ្វីលីពីន ថៃ ឡាវ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងកូរ៉េ ជាពិសេសវគ្គបណ្តុះបណ្តាលអនឡាញ FSI-Connect ដែលរៀបចំដោយធនាគារសម្រាប់ការជាត់ទាត់អន្តរជាតិ (BIS) និងជំនាញផ្សេងៗដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ។ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗ រួមមាន វគ្គបណ្តុះបណ្តាលផ្ទាល់នឹងការងារ (on-the-job training) វគ្គសុក្រឹតការ ឬវគ្គធនាគារកណ្តាល វគ្គបាគងស្តីពីការត្រួតពិនិត្យធនាគារ វគ្គគូលែនស្តីពីភាពជាអ្នកដឹកនាំ និងវគ្គចែករំលែកចំណេះដឹង។ ក្នុងគម្រោងអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង ធនាគារជាតិនៃកម្ពុជាបាននិងកំពុងផ្តល់ឱកាសដល់មន្ត្រីនូវការអប់រំនៅក្នុងស្រុក ដូចជាជំនាញគណនេយ្យ ACCA (the Association of Chartered Certified Accounts) និងក្រៅស្រុក តាមរយៈអាហារូបករណ៍ថ្នាក់អនុបណ្ឌិតនិងបណ្ឌិត លើជំនាញធនាគារ ហិរញ្ញវត្ថុ គណនេយ្យ សេដ្ឋកិច្ច និងព័ត៌មានវិទ្យា ជាដើម។

### ៤.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយដៃគូអភិវឌ្ឍន៍ដូចជា មជ្ឈមណ្ឌល SEACEN មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (Alliance for Financial Inclusion - AFI) ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លីលើប្រធានបទសំខាន់ៗ ពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារនិងអភិបាលកិច្ច ក៏ដូចជាប្រធានបទពាក់ព័ន្ធផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារ។ ក្នុងឆ្នាំ២០១៨ កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា រួមមាន៖

១/. មជ្ឈមណ្ឌល SEACEN សហការជាមួយធនាគារជាតិនៃកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពី "ការត្រួតពិនិត្យផ្អែកលើហានិភ័យ" ដោយមានការចូលរួមចែករំលែកបទពិសោធន៍ពីធនាគារកណ្តាលម៉ាឡេស៊ី។ ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីត្រួតពិនិត្យក្មេងៗ

ចូលរួមវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពត្រួតពិនិត្យដល់មន្ត្រីនៃអគ្គនាយកដ្ឋានត្រួតពិនិត្យលើសមត្ថភាពអនុវត្តការងារបច្ចុប្បន្នបន្ថែមទៀត។

២/. ក្នុងនាមជាសមាជិកពេញលេញរបស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (Alliance for Financial Inclusion - AFI) ធនាគារជាតិនៃកម្ពុជាបាន៖

- រៀបចំកិច្ចប្រជុំក្រុមការងាររបស់ AFI ចំនួន ២ គឺ ១.ក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ (FISPLG) និង ២.ក្រុមការងាររៀបចំបទដ្ឋានរួមសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ (GSP) ដោយមានការចូលរួមពីអ្នករៀបចំគោលនយោបាយ បញ្ញត្តិករ មន្ត្រីត្រួតពិនិត្យ ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ និងស្ថាប័នស្រាវជ្រាវអន្តរជាតិសរុបប្រមាណ ៩០ រូប មកពីប្រទេស ៤៣ ដែលជាសមាជិករបស់ AFI។
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការជាន់ខ្ពស់ ស្តីពី បរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី រួមមានកិច្ចប្រជុំប្រចាំឆ្នាំ កិច្ចប្រជុំក្រុមការងារ និងវេទិកាពិភាក្សាគោលនយោបាយសកលប្រចាំឆ្នាំ២០១៨ របស់ AFI។
- ចូលរួមកិច្ចប្រជុំពិភាក្សាអំពី "បរិយាប័ន្នហិរញ្ញវត្ថុនិងហិរញ្ញប្បទានបៃតង" របស់ AFI ដែលផ្តោតលើកិច្ចពិភាក្សាអំពីគោលនយោបាយ និងវិធីសាស្ត្រលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ជាពិសេសការជំរុញការផ្តល់ហិរញ្ញប្បទានបៃតង និងសេដ្ឋកិច្ចបៃតង។

៣/. ក្នុងនាមជាសមាជិកគណៈកម្មាធិការប្រតិបត្តិរបស់សមាគមឥណទានកសិកម្មនិងជនបទសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Rural and Agricultural Credit Association – APRACA) ធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ និងវេទិកាពិភាក្សាអំពី "ដំណោះស្រាយនៃការផ្តល់ហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម" ដែលលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការបានសម្រេចឲ្យធនាគារអភិវឌ្ឍន៍កសិកម្មចិន បង្កើតវិទ្យាស្ថានមួយជាបុត្តសម្ព័ន្ធរបស់សមាគម ដោយវិទ្យាស្ថាននេះផ្តោតលើការស្រាវជ្រាវអំពីគោលនយោបាយលើកកម្ពស់ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្មសម្រាប់ចែករំលែកដល់ប្រទេសជាសមាជិករបស់សមាគម។

៤/. ក្នុងនាមជាស្ថាប័នដឹកនាំសិក្សាបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើនៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកមិនពេញលេញ (Associate Member) សមាគមអន្តរជាតិសម្រាប់កិច្ចការពារប្រាក់បញ្ញើ (International Association of Deposit Insurers – IADI) ក្នុងគោលបំណងទទួលបានការបណ្តុះបណ្តាល និងការរៀនសូត្រ អំពីបណ្តាប្រទេសជាសមាជិកផ្សេងៗពាក់ព័ន្ធនឹងការបង្កើត ការត្រួតពិនិត្យ និងការគ្រប់គ្រងប្រព័ន្ធការពារប្រាក់បញ្ញើ ស្របពេលដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងសិក្សារៀបចំបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើនេះ។

ឆ្លងតាមកិច្ចសហប្រតិបត្តិការខាងលើ ធនាគារជាតិនៃកម្ពុជានៅតែបន្តនិងពង្រឹងកិច្ចសហប្រតិបត្តិការ ទាំងក្នុងនិងក្រៅប្រទេស សំដៅលើកកម្ពស់ភាពរឹងមាំនៃប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការកសាងសមត្ថភាពធនធានមនុស្ស ដោយការបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល និងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការងារនានា ដែលបានមកពីការរពង្រីកបណ្តាញទំនាក់ទំនងជាមួយអាជ្ញាធរត្រួតពិនិត្យក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ។

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១

ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០១៨

(នៅផ្នែកភាសាអង់គ្លេស)

## ឧបសម្ព័ន្ធ២ (ក) និង ២ (ខ)

អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទាន ជាប្រាក់រៀលនិងរូបិយបណ្ណ

(នៅផ្នែកភាសាខ្មែរ)

## ឧបសម្ព័ន្ធ៣

ប្រព័ន្ធធនាគារកម្ពុជា

(នៅផ្នែកភាសាខ្មែរ)

## ឧបសម្ព័ន្ធ៤

បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

(នៅផ្នែកភាសា)

## ឧបសម្ព័ន្ធ៥

ឈ្មោះគ្រឹះស្ថានដែលបានសុំឈប់ និងដកអាជ្ញាបណ្ណ

(នៅផ្នែកភាសាខ្មែរ)

## ឧបសម្ព័ន្ធ៦

បញ្ជីលេខទូរស័ព្ទទំនាក់ទំនងអំពីចម្ងល់ និងបញ្ហាពាក់ព័ន្ធនឹង
ការប្រើប្រាស់សេវាហិរញ្ញវត្ថុ

(នៅផ្នែកភាសាខ្មែរ)

# ឧបសម្ព័ន្ធ ២ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០១៨)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | ឥណទានជាដុល្លារ | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ |
| **ធនាគារពាណិជ្ជ** | | | | | | | | | | |
| 1 | ធនាគារ អេស៊ីលីដា ភីអិលស៊ី | 17.5% | 17.6% | 12.7% | 12.9% | 12.7% | 10.5% | | 18.1% | |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 11.0% | 12.5% | 12.2% | 8.3% | 11.9% | 11.5% | | | |
| 3 | ធនាគារ អេ អ៊ិន ហ្សែត រ៉ូយ៉ាល់ (កម្ពុជា) | | | | | 7.7% | 7.5% | | | |
| 4 | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | | | | | 6.0% | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | | | | | | | | | |
| 6 | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | | | | 8.1% | 8.7% | 8.6% | | | |
| 7 | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | | | | 6.0% | 7.6% | 7.4% | | | |
| 8 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | 7.5% | 8.0% | | | |
| 9 | ធនាគារ ប៉ូយ៉ុង ខ្មែរ | | | | 9.0% | 8.8% | | | | |
| 10 | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | | | | | | | | | |
| 11 | សាខាធនាគារ មីហ្ស៊ូហូ អិលធីឌី | | | | | | | | | |
| 12 | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | | | | | 10.4% | 7.1% | | | |
| 13 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | | | | |
| 14 | ធនាគារ មេគង្គកម្ពុជា មហាជន ទទួលខុសត្រូវមានកំរិត | | 9.0% | | 13.0% | | | | | |
| 15 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 17.4% | 15.4% | 12.2% | 13.9% | 14.2% | 11.8% | 15.8% | 15.0% | 12.2% |
| 16 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | | | | 7.8% | 7.9% | | | | |
| 17 | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | 9.0% | 8.3% | 8.1% | | 8.4% | 8.4% | | | |
| 18 | ធនាគារ កាណាឌីយ៉ា ក.អ | | | | 10.0% | 5.1% | 6.7% | | | |
| 19 | សាជីវកម្មធនាគារកាថេយូណៃធីតកម្ពុជា ចំកាត់ | | 8.2% | 8.8% | 9.0% | 8.0% | 8.4% | | | |
| 20 | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | 8.8% | 10.2% | 9.5% | 8.4% | 8.9% | 8.4% | | | |
| 21 | ធនាគារ ស៊ីអាយអ៊ឹមប៊ី ភីអិលស៊ី | | | | | 7.4% | 7.3% | | | |
| 22 | ធនាគារ ពាណិជ្ជទី១ សាខាភ្នំពេញ | | | | 6.8% | 6.8% | 7.0% | | | |
| 23 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | 9.0% | 10.4% | 10.1% | 12.8% | 9.0% | 9.4% | | | |
| 24 | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | | 10.6% | 7.2% | | 6.5% | 7.6% | | | |
| 25 | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | | | | | 7.4% | 7.3% | | | |
| 26 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | | | | 9.5% | 7.0% | 6.3% | | | |
| 27 | ធនាគារ ក្រុងថៃ ចំកាត់ (មហាជន) សាខាភ្នំពេញ | | | | | | 5.1% | | | |
| 28 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | | | | 7.6% | 7.4% | 8.3% | | | |
| 29 | ធនាគារ អ៊ឹមប៊ី ភីអិលស៊ី សាខាភ្នំពេញ កម្ពុជា | | | | | 10.0% | | | | |
| 30 | ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ | | | | | 7.4% | 7.8% | | | |

# ឧបសម្ព័ន្ធ ២ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ (ប្រាក់រៀល និងរូបិយប័ណ្ណ)

(ប្រចាំខែធ្នូ ឆ្នាំ២០១៨)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | ឥណទានជាដុល្លារ | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ | <១ឆ្នាំ | ១ ដល់ ៥ឆ្នាំ | >៥ឆ្នាំ |
| 31 | ធនាគារ ហ្វីលីព ភីអិលស៊ី | | 8.5% | 9.5% | 8.7% | 9.5% | 8.9% | | | |
| 32 | ធនាគារ ភ្នំពេញ ពាណិជ្ជ | 5.3% | 5.3% | | 10.5% | 12.0% | 9.4% | | | |
| 33 | ធនាគារ ព្រីនស៍ ម.ក | 18.0% | 14.7% | 12.1% | 13.2% | 12.6% | 11.3% | | | |
| 34 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា | | 8.3% | 8.2% | | 8.9% | 9.3% | | | |
| 35 | ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី | 11.4% | 10.6% | 8.7% | 9.2% | 9.7% | 8.7% | | | |
| 36 | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី | | | | 6.4% | 8.0% | 8.0% | | | |
| 37 | ធនាគារ ស្ថាបនា ភីអិលស៊ី | 17.9% | 17.4% | 14.3% | 17.3% | 15.7% | 11.9% | 18.0% | 18.1% | 16.9% |
| 38 | ធនាគារ ស៊ិនហានខ្មែរ (ខេមបូឌា) ម.ក | | 8.0% | 8.0% | 7.6% | 8.0% | 8.0% | | | |
| 39 | ធនាគារ តៃវ៉ាន់ខូអបភើរេធីវ សាខាភ្នំពេញ | 7.0% | 7.1% | 7.5% | 7.0% | 7.5% | 7.7% | | | |
| 40 | ធនាគារ សហពាណិជ្ជ ក.អ | | | | 7.7% | 6.8% | 8.0% | | | |
| 41 | ធនាគារ វឌ្ឍនៈ | | | | | 11.0% | 5.8% | | | |
| 42 | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង) | | | | 7.4% | 7.7% | 7.3% | | | |
| **ធនាគារឯកទេស** | | | | | | | | | | |
| 43 | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី | | | | | | | | | |
| 44 | ធនាគារឯកទេស អានកូ | | | | 16.6% | 16.6% | 13.8% | | | |
| 45 | ធនាគារឯកទេស អង្គរ កាពីតាល | | | | 36.0% | 13.0% | 6.0% | | | |
| 46 | ធនាគារឯកទស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី | | | | 8.0% | 8.5% | 8.4% | | | |
| 47 | ធនាគារឯកទេស ខេមខូ ម.ក | | | | | 8.8% | 10.6% | | | |
| 48 | ធនាគារឯកទេស ឌីជីប៊ី ម.ក | 18.0% | 18.0% | | 13.8% | 14.0% | | | | |
| 49 | ធនាគារឯកទេស វិនិយោគទីមួយ | | | | | | | | | |
| 50 | ធនាគារឯកទេស ខេប៊ី ដេហាន ម.ក | | | | 12.0% | 12.0% | | | | |
| 51 | ធនាគារឯកទស ខ្មែរ ភីអិលស៊ី | | | | | 9.0% | | | | |
| 52 | ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រ៊ិដ ភីអិលស៊ី | | | | | 10.5% | 8.9% | | | |
| 53 | ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី ចំកាត់ | | | | | | | | | |
| 54 | ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ | | 9.0% | | | 8.2% | 7.6% | | | |
| 55 | ធនាគារឯកទេស សាវធើន ខាប់ភីផល ភីអិលស៊ី | | | | 10.7% | 9.0% | 7.7% | | | |
| 56 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | | | | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | **11.3%** | **15.7%** | **10.0%** | **7.8%** | **11.6%** | **9.3%** | **16.8%** | **15.9%** | **12.9%** |

# ឧបសម្ព័ន្ធ ២ ខ

## អត្រាការប្រាក់លើប្រាក់បញ្ញើ (ប្រាក់រៀល និងរូបិយប័ណ្ណ)

(ប្រចាំខែធ្នូ ឆ្នាំ២០១៨)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| ធនាគារពាណិជ្ជ | | | | | | | | | | | | | | | | |
| 1 | ធនាគារ អេស៊ីលីដា ភីអិលស៊ី | 0.5% | 2.0% | 3.6% | 4.3% | 5.9% | 0.3% | 0.8% | 2.0% | 3.1% | 4.7% | 0.2% | | 0.5% | 1.0% | 2.0% |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 0.9% | 2.3% | 3.8% | 4.7% | 6.2% | 0.9% | 0.8% | 2.1% | 3.3% | 4.8% | | | | | |
| 3 | ធនាគារ អេ អិន ហ្សែត រ៉ូយ៉ាល់ (កម្ពុជា) | | 0.6% | 3.3% | 4.0% | 1.3% | 0.2% | 3.0% | 0.2% | 1.2% | 1.5% | | | | 2.7% | 1.3% |
| 4 | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | | | | | | 1.0% | | 2.0% | 3.0% | 4.5% | | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | | | | | | 1.0% | 2.0% | 3.2% | 8.4% | 7.6% | | | | | |
| 6 | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | | | 2.3% | 4.3% | 6.4% | | 1.9% | 2.7% | 4.1% | 5.7% | | | | | |
| 7 | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | 0.1% | | | | | 0.5% | 1.2% | 1.5% | 2.9% | 3.5% | 0.2% | 1.5% | 3.3% | 3.2% | 3.0% |
| 8 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | 0.8% | 2.0% | | | 2.8% | | | | | |
| 9 | ធនាគារ ប៉ូយ៉ុង ខ្មែរ | 1.0% | | | | | 1.0% | | | | | | | | | |
| 10 | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | 0.3% | | | | | 0.1% | | 1.0% | | | | | | | |
| 11 | សាខាធនាគារ មីហ្សូហូ អិលធីឌី | | | | | | | | | | | | | | | |
| 12 | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | 1.8% | | 2.5% | 5.0% | 6.0% | 2.1% | | 3.5% | 3.2% | 5.0% | 0.4% | | | 0.7% | 2.5% |
| 13 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | 1.5% | | | | | 1.5% | 2.1% | 3.2% | 4.2% | 5.8% | | | | | |
| 14 | ធនាគារ មេគង្គកម្ពុជា មហាជន ទទួលខុសត្រូវមានកំរិត | 3.7% | | 11.0% | 11.0% | 11.0% | 2.0% | 3.4% | 3.4% | 3.7% | 4.0% | | | | | |
| 15 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 2.0% | 2.0% | 3.0% | 3.3% | 6.5% | 0.6% | 2.0% | 4.0% | 4.7% | 5.8% | 2.0% | | 3.1% | 4.1% | 5.5% |
| 16 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | | | 1.0% | | | 0.8% | 1.4% | 1.5% | 1.7% | | | | 1.0% | | |
| 17 | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | 0.5% | 1.5% | 3.2% | 3.8% | 4.8% | 0.2% | 0.7% | 1.5% | 2.8% | 3.5% | 0.5% | | | | |
| 18 | ធនាគារ កាណាឌីយ៉ា ក.អ | 2.0% | | 4.1% | 5.7% | 6.8% | 0.8% | 1.3% | 2.3% | 4.0% | 4.9% | 0.3% | 1.0% | 1.5% | 2.0% | 3.2% |
| 19 | សាជីវកម្មធនាគារកាថេយ្យូណៃធីតកម្ពុជា ចំកាត់ | 2.0% | | 5.0% | 6.0% | 7.0% | 0.5% | | 1.9% | 2.5% | 3.9% | | | | | |
| 20 | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | 1.5% | 3.0% | 5.0% | | 6.3% | 0.8% | 2.5% | 2.7% | 4.4% | 5.0% | | | | | |
| 21 | ធនាគារ ស៊ីអាយអឹមប៊ី ភីអិលស៊ី | | | 4.3% | 5.4% | 7.0% | 0.5% | 1.5% | 2.2% | 3.4% | 4.2% | | | | | 1.6% |
| 22 | ធនាគារ ពាណិជ្ជទី១ សាខាភ្នំពេញ | | | | | | | 4.0% | 5.5% | 4.4% | 5.2% | | | | | |
| 23 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | 1.3% | 2.0% | 3.5% | 4.5% | 6.6% | 1.0% | 1.7% | 3.0% | 3.9% | 5.0% | | | | | |
| 24 | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | 1.1% | | 4.0% | | 5.8% | 0.8% | 1.9% | 2.8% | 3.8% | 5.0% | | | | | |
| 25 | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | | 3.0% | 4.3% | | | | 1.5% | 2.7% | 2.6% | 3.5% | | 2.4% | 2.5% | | |
| 26 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 0.7% | | | | | 0.6% | 1.8% | 2.9% | 2.2% | 3.3% | | | | | |
| 27 | ធនាគារ ក្រុងថៃ ចំកាត់ (មហាជន) សាខាភ្នំពេញ | | | | | | 0.1% | | 0.5% | 0.8% | | | | | | |
| 28 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | 1.2% | 2.3% | 3.3% | 3.5% | | 0.5% | 1.3% | 1.8% | 3.0% | 3.6% | | | | | |
| 29 | ធនាគារ អ៊ឹមប៊ី ភីអិលស៊ី សាខាភ្នំពេញ កម្ពុជា | | 4.9% | | | 6.0% | | 3.9% | 4.2% | 4.7% | 5.0% | | | | | |
| 30 | ធនាគារ មេហ្គា អិនធើណេសិនណល ខមមើសល សាខាភ្នំពេញ | | | | | | | | 1.1% | 2.3% | 1.1% | | | | | |

# ឧបសម្ព័ន្ធ ២ ខ

## អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០១៨)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 31 | ធនាគារ ហ្វីលីព ភីអិលស៊ី | 1.3% | | | | | 1.0% | 2.8% | 2.6% | 3.4% | 5.2% | | | | | |
| 32 | ធនាគារ ភ្នំពេញ ពាណិជ្ជ | 1.2% | | 3.3% | 4.3% | 5.5% | 0.9% | 1.0% | 3.0% | 4.0% | 4.9% | | | | | |
| 33 | ធនាគារ ព្រីនស៍ ម.ក | | | | | | | | | | | | | | | |
| 34 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា | 1.0% | 3.5% | 4.0% | 5.0% | 6.2% | 0.5% | 1.5% | 2.1% | 3.1% | 4.9% | | | | | |
| 35 | ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី | 0.5% | 6.5% | 4.0% | 4.3% | 5.2% | 0.5% | 4.7% | 4.8% | 5.1% | 5.5% | | | | | |
| 36 | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី | | | | | | | 1.5% | 4.7% | 4.9% | 5.6% | | | | | |
| 37 | ធនាគារ ស្ថាបនា ភីអិលស៊ី | 1.5% | 3.5% | 4.0% | 6.3% | 7.2% | 1.0% | 3.0% | 3.4% | 4.3% | 6.3% | 1.0% | 3.0% | 3.5% | 3.3% | 3.2% |
| 38 | ធនាគារ ស៊ិនហានខ្មែរ (ខេមបូឌា) ម.ក | 0.1% | | | | | 0.2% | | 2.1% | 2.3% | | | | | | |
| 39 | ធនាគារ តៃវ៉ាន់ខូអបភើរេធីវ សាខាភ្នំពេញ | 0.1% | | | | | 0.4% | 3.1% | 2.6% | 2.1% | 1.9% | | | | | |
| 40 | ធនាគារ សហពាណិជ្ជ ក.អ | 1.3% | | | 3.8% | 4.5% | 1.0% | | 2.0% | 2.5% | 3.1% | 1.0% | | | | |
| 41 | ធនាគារ វឌ្ឍនៈ | 0.5% | 1.5% | | 3.0% | 3.5% | 0.6% | 1.7% | 2.3% | 3.2% | 4.3% | | | | | |
| 42 | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៉ែង) | 0.5% | | | | | 0.5% | | 2.5% | 3.3% | | | | | | |
| **ធនាគារឯកទេស** | | | | | | | | | | | | | | | | |
| 43 | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី | | | | | | | | | | | | | | | |
| 44 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 45 | ធនាគារឯកទេស អង្គរ កាពីតាល | | | | | | | | | | | | | | | |
| 46 | ធនាគារឯកទស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី | | | | | | | | | | | | | | | |
| 47 | ធនាគារឯកទេស ខេមខូ ម.ក | | | | | | | | | | | | | | | |
| 48 | ធនាគារឯកទេស ឌីជីប៊ី ម.ក | | | | | | | | | | | | | | | |
| 49 | ធនាគារឯកទេស វិនិយោគទីមួយ | | | | | | | | | | | | | | | |
| 50 | ធនាគារឯកទេស ខេប៊ី ដេហាន ម.ក | | | | | | | | | | | | | | | |
| 51 | ធនាគារឯកទស ខ្មែរ ភីអិលស៊ី | | | | | | | | | | | | | | | |
| 52 | ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រ៊ិដ ភីអិលស៊ី | | | | | | | | | | | | | | | |
| 53 | ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី ចំកាត់ | | | | | | | | | | | | | | | |
| 54 | ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ | | | | | | | 3.0% | 3.5% | 4.0% | 5.0% | | | | | |
| 55 | ធនាគារឯកទេស សារធើន ខាប់ភីផល ភីអិលស៊ី | | | | | | | | | | | | | | | |
| 56 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | | | | | | | | | | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | **1.0%** | **2.6%** | **3.8%** | **5.3%** | **6.4%** | **0.6%** | **2.0%** | **2.5%** | **3.4%** | **4.8%** | **0.3%** | **1.6%** | **2.0%** | **1.9%** | **3.3%** |

# ឧបសម្ព័ន្ធ ៣

## ប្រព័ន្ធធនាគារនៅកម្ពុជា

### ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

**ធនាគារជាតិនៃកម្ពុជា**
**(ធនាគារកណ្ដាល)**

**៤៣ ធនាគារពាណិជ្ជ**

**១៣ សាខាធនាគារបរទេស**

១. ធនាគារ ពាណិជ្ជទី១ សាខាភ្នំពេញ
២. ធនាគារ ក្រុងថៃ ចំកាត់ (មហាជន) សាខាភ្នំពេញ
៣. ធនាគារ ឥណ្ឌា សាខាភ្នំពេញ
៤. ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ
៥. ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមើសល សាខាភ្នំពេញ
៦. ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ
៧. ធនាគារ អ៊ឹមប៊ី ភីអិលស៊ី សាខាភ្នំពេញ កម្ពុជា
៨. ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ
៩. ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា
១០. សាខាធនាគារ កសិកន ផាប់ប្លីក ខមភេនី លីមីតធីត (ភ្នំពេញ)
១១. សាខាធនាគារមីហ្ស៊ូហូ អិលធីឌី
១២. ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីបែ៊ង)
១៣. សាខាធនាគារ អ៊ិនដាសស្រៀល បែ៊ង អហ្វ ខូរៀ "ភ្នំពេញ"

**១៣ បង្កើតឡើងក្នុងស្រុក**

១. ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
២. ធនាគារ កម្ពុជាអាស៊ី ចំកាត់
៣. ធនាគារ កាណាឌីយ៉ា ក.អ
៤. ធនាគារ មេគង្គកម្ពុជា មហាជន ទទួលខុសត្រូវមានកម្រិត
៥. ធនាគារ វឌ្ឍនៈ
៦. ធនាគារ អេស៊ីលីដា ភីអិលស៊ី
៧. ធនាគារ ស្ថាបនា ភីអិលស៊ី
៨. ធនាគារ ប៊ូយ៉ុង ខ្មែរ
៩. ធនាគារ ភ្នំពេញ ពាណិជ្ជ
១០. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
១១. ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក
១២. ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) បែ៊ង ម.ក
១៣. ធនាគារ ព្រីនស៍ ម.ក

**១៧ បុត្តសម្ព័ន្ធធនាគារ**

១. ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់
២. ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
៣. ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី
៤. ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ (កម្ពុជា)
៥. ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់
៦. ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
៧. ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក
៨. ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី
៩. ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា
១០. ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
១១. ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី
១២. ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
១៣. សាជីវកម្មធនាគារកាថេយយូណៃធីតកម្ពុជា ចំកាត់
១៤. ធនាគារ សហពាណិជ្ជ ក.អ
១៥. ធនាគារ ហ្វីលីព ភីអិលស៊ី
១៦. ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី (អេស អេជ ប៊ី)
១៧. ធនាគារ ប្រេដ បែ៊ង (ខេមបូឌា) ភីអិលស៊ី

**១៤ ធនាគារឯកទេស**

**១ ធនាគាររដ្ឋ**

១. ធនាគារ អភិវឌ្ឍន៍ជនបទ

**៥ បង្កើតឡើងក្នុងស្រុក**

១. ធនាគារឯកទេស វិនិយោគទី១
២. ធនាគារឯកទេស អានកូ
៣. ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត
៤. ធនាគារឯកទេស ខ្មែរ ភីអិលស៊ី
៥. ធនាគារឯកទេស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី

**៨ ធនាគារបរទេស**

១. ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី
២. ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
៣. ធនាគារឯកទេស អង្គរ កាពីតាល
៤. ធនាគារឯកទេស ខេមខូ ម.ក
៥. ធនាគារឯកទេស ឌី ជី ប៊ី ម.ក
៦. ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រិដ ភីអិលស៊ី
៧. ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
៨. ធនាគារឯកទេស សាវធើន យែភីថល ភីអិលស៊ី

**៥ ការិយាល័យតំណាង**

១. ធនាគារ ស្តង់ដារឆាទីវ៉េត
២. ធនាគារ វិនិយោគនិងអភិវឌ្ឍន៍នៃវៀតណាម
៣. ធនាគារ អ៊ឹមយូអេហ្វជី បែ៊ង អិលធីឌី
៤. ធនាគារ ស៊ូមីតូម៉ូ មីតស៊ុយ បែ៊ងឃីង ខបភើរេសិន
៥. ធនាគារ សៀងហៃ ខមមែសល & សេវវីង

**២.៧៧៩ អាជីវកម្មប្តូរប្រាក់**

**សរុបភ្នំពេញ : ១២៩**

-អាជ្ញាបណ្ណ
- ធនាគារ ២៥
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២៥
- នីតិ/ រូបវន្តបុគ្គល ២៣

-លិខិតអនុញ្ញាត : ៥៦

**សរុបសាខាខេត្ត : ២.៦៥០**

-អាជ្ញាបណ្ណ : 0

-លិខិតអនុញ្ញាត : ២.៦៥០

សម្គាល់:

- ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានក្លាយខ្លួនពី ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
- ធនាគារ ព្រីនស៍ ម.ក បានក្លាយខ្លួនពី ព្រីនស៍ មីក្រូហ្វាយនែន
- ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក បានប្តូរឈ្មោះពី ធនាគារ ស៊ិនហានខ្មែរ
- ធនាគារឯកទេស ខេប៊ី ដេហាន ម.ក បានប្តូរឈ្មោះពី ធនាគារឯកទេស តូម៉ាតូ

## ៨១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ៧៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

១. សីលានិធិ លីមីធីត
២. វីលខម ហ្វាយនែន (ខេមបូឌា) ម.ក
៣. ម៉ាក់ស៊ីម៉ា ភីអិលស៊ី
៤. ឥណទានពលរដ្ឋរុងរឿង អិលធីឌី
៥. ណុងហឹប ហ្វាយនែន (ខេមបូឌា) ម.ក
៦. ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក
៧. ហ្វាមើរ ហ្វាយនែន អិលធីឌី
៨. អាតូម ខែភីថល ម.ក
៩. ហ្វឺស ហ្វាយនែន ភីអិលស៊ី
១០. វ៉ាយស៊ីភី ម៉ាយក្រូហ្វាយនែន ម.ក
១១. សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត
១២. ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត
១៣. ខេមរៈ លីមីតធីត
១៤. ប្រាយម៍ អិមអេហ្វ អិលធីឌី
១៥. សូណាត្រា ភីអិលស៊ី
១៦. អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី
១៧. ចម្រើន ម.ក
១៨. អាក់ទីវ ភីភល ភីអិលស៊ី
១៩. បាយ៉ន គ្រេឌីត លីមីធីត
២០. បរិបូរណ៍ ភីអិលស៊ី
២១. ឃ្វីន ហ្វាយនែន ម.ក
២២. ស៊ីធី ភីអិលស៊ី
២៣. លី ហួរ ភីអិលស៊ី
២៤. អមតៈខាប់ភីថល ភីអិលស៊ី
២៥. សច្ចៈ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
២៦. អរ្ស៊ូ ហ្វាយនែនខប ភីអិលស៊ី
២៧. និរន្តរ ភីអិលស៊ី
២៨. ខ្មែលតា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
២៩. សេនជូរី ខេមបូ ឌីវេឡុបមេន ភីអិលស៊ី
៣០. តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣១. ពិភពថ្មី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣២. សិរីឧត្តម មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣៣. សម្បត្តិ ហ្វាយនែន ភីអិលស៊ី
៣៤. ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី
៣៥. ប៉ែមប៊ូ ហ្វាយនែន ភីអិលស៊ី
៣៦. សហគ្រិនភាព ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣៧. ឆាយលីស រ៉ូយ៉ាល់ ហ្វាយនែន ភីអិលស៊ី
៣៨. ធីប៊ីប៊ី (ខេមបូឌា) ភីអិលស៊ី
៣៩. មហានគរ ម.ក
៤០. រ៉ូយ៉ាល់ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៤១. សាន់នី ម៉ាយក្រូហ្វាយនែន ម.ក
៤២. ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៤៣. សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា ភីអិលស៊ី
៤៤. សាមគ្គី ម៉ាយក្រូហ្វាយនែន អ៊ិនស៊ីធ្យូសិន ភីអិលស៊ី
៤៥. ខេមបូឌាន ឡេប៊ីយែរ៍ ភីអិលស៊ី
៤៦. ខឺលេកធីវ វីន (ខេមបូឌា) ភីអិលស៊ី
៤៧. អេស៊ា ផេស៊ីហ្វិក ហ្វាយនែន ភីអិលស៊ី
៤៨. ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៤៩. អ៊ីខ្មែមីតស៊ុ សេហ្សុង ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
៥០. ម៉ាខ្មែរ ហ្វាយនែនសល យេផេន ភីអិលស៊ី
៥១. សហការ ភីអិលស៊ី
៥២. ហ្គោលដិន ឃែស ភីអិលស៊ី
៥៣. ជោគជ័យ ហ្វាយនែន ភីអិលស៊ី
៥៤. សប្បាយ គ្រេឌីត ខមមើសល ភីអិលស៊ី
៥៥. ជេត ឃែស បកស៍ ហ្វាយនែន ភីអិលស៊ី
៥៦. លីដ ភីអិលស៊ី
៥៧. អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៥៨. ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
៥៩. ធី&ហ្គ ហ្វាយនែន ភីអិលស៊ី
៦០. អនាគត ភីអិលស៊ី
៦១. ហ្គ្រេវ ម.ក
៦២. បៃតង មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៦៣. មីយ៉ា ហ្វាយនែនសល ភីអិលស៊ី
៦៤. ពន្លឺចតុមុខ ភីអិលស៊ី
៦៥. វិថី ម៉ាយក្រូហ្វាយនែន ម.ក
៦៦. ទ្រព្យខ្ញុំ ម.ក
៦៧. ខ្មែរ ឃែភីថល ម .ក
៦៨. ភីជី ឌីវេឡុបម៉ិន ម.ក
៦៩. ជេស៊ី ហ្វាយនែន ម.ក
៧០. ស៊ីអិមខេ ម.ក
៧១. រ៉ូល្យា ម.ក
៧២. ធីតា ស្រីសាវ៉ាត ម៉ាយក្រូហ្វាយនែន ម.ក
៧៣. ហ្វាមីលី ម.ក
៧៤. ប្រពៃ ម៉ាយក្រូហ្វាយនែន ម.ក

### ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

១. អម្រឹត ម.ក
២. ហត្ថាកសិករ លីមីតធីត
៣. អេ អឹម ខេ ភីអិលស៊ី
៤. ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក
៥. គ្រេឌីត ភីអិលស៊ី
៦. ប្រាសាក់
៧. អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ២៧៣ គ្រឹះស្ថានឥណទានជនបទ

## ១៥ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

១. ជីអិល ហ្វាយនែន ភីអិលស៊ី
២. ប៊ីអេសភី ហ្វាយនែន (ខេមបូឌា) ម.ក
៣. មេហ្គា លីស៊ីង ភីអិលស៊ី
៤. សួស្តី ហ្វាយនែន ភីអិលស៊ី
៥. ខេខេ ហ្វាន់ លីស៊ីង ភីអិលស៊ី
៦. តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
៧. អេលីន លីស៊ីង ភីអិលស៊ី
៨. អាយ-ហ្វាយនែន លីស៊ីង ភីអិលស៊ី
៩. លី ហួរ លីស៊ីង ភីអិលស៊ី
១០. ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក
១១. ជេកស៍ ហ្វាយនែន (ខេមបូឌា) ម.ក
១២. ខូម៉ាត់ស៊ុ លីស៊ីង (ខេមបូឌា) ម.ក
១៣. គូបូតា លីស៊ីង (ខេមបូឌា) ម.ក
១៤. អិល អូ ឌី លីស៊ីង ម.ក
១៥. អភីធីអិន អ៊ីឡាយអិន ហ្វាយនែនសល លីស៊ីង ម.ក

## ក្រុមហ៊ុន គ្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី

## ២១ សាខាធនាគារជាតិនៅតាមខេត្ត

១. ភ្នំពេញ
២. កំពង់ចាម
៣. ព្រះសីហនុ
៤. សៀមរាប
៥. បាត់ដំបង
៦. បន្ទាយមានជ័យ
៧. ស្វាយរៀង
៨. កណ្តាល
៩. កំពត
១០. កំពង់ធំ
១១. ពោធិសាត់
១២. កំពង់ស្ពឺ
១៣. កោះកុង
១៤. រតនៈគីរី
១៥. ព្រៃវែង
១៦. តាកែវ
១៧. កំពង់ឆ្នាំង
១៨. ព្រះវិហារ
១៩. ក្រចេះ
២០. ស្ទឹងត្រែង
២១. មណ្ឌលគីរី

## ១០ ក្រុមហ៊ុនសវនកម្ម

១. ក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់ (ខេភីអឹមជី)
២. ក្រុមហ៊ុន ម៉ូរីសុន កាក់ & អាសូស្យេរ
៣. ក្រុមហ៊ុន ប្រាយវ៉ តធ័រហោវខូភើស៍ (ខេមបូឌា)
៤. ក្រុមហ៊ុនសវនកម្ម អង្គរ ស៊ីធីហ្វាយ អ៊ីខោនចឹន ណេតវើក អិមស៊ីមីលលែនវូដ (ខេមបូឌា)
៥. ក្រុមហ៊ុន អឹនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)
៦. ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត
៧. ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត
៨. ក្រុមហ៊ុន ឌីឡ៉ូយធ៍ (ខេមបូឌា) ខូ អិលធីឌី
៩. ក្រុមហ៊ុន អេចអឌីភី & អឹសូស៊ីអេត
១០. ក្រុមហ៊ុន គ្រូវ (ខេអេច) ឯ.ក

## ៥ តតិយភាគី

១. ក្រុមហ៊ុន Western Union
២. ក្រុមហ៊ុន Money Gram
៣. ក្រុមហ៊ុន IME
៤. ក្រុមហ៊ុន Express Money
៥. ក្រុមហ៊ុន Continental Exchange Solutions, Inc. dba RIA Financial Services

## ១៦ គ្រឹះស្ថានផ្តល់សេវាទូទាត់

១. គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក
២. គ្រឹះស្ថាន លី ហួរ ផេ ប្រ៉ូ ភីអិលស៊ី
៣. គ្រឹះស្ថាន ផាយ ផេ ខូអិលធីឌី
៤. គ្រឹះស្ថាន ស្មាត អាត្យាតា ខូអិលធីឌី
៥. គ្រឹះស្ថាន អេស៊ា ឃែស អិចប្រេស ខូអិលធីឌី
៦. គ្រឹះស្ថាន ស៊ីធេល ហ្វាយនែនសល ស៊ើវីស ម.ក
៧. គ្រឹះស្ថាន ស្ពីត ផេ ម.ក
៨. គ្រឹះស្ថាន កាណាឌីយ៉ា-ហ្វុលលើតុន ម៉ូបែល ម៉ាន់នី ម.ក
៩. គ្រឹះស្ថាន ឃ្យូប៊ីល ម.ក
១០. គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក
១១. គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក
១២. គ្រឹះស្ថាន បងឡួយ ផេមិុន ម.ក
១៣. គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណឡជី ម.ក
១៤. គ្រឹះស្ថាន ហួយវ៉ន ផេ ម.ក
១៥. គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិុន សឹលូសិន ម.ក
១៦. គ្រឹះស្ថាន ផេហ្គោ ស៊ី (ខេមបូឌា) ខូអិលធីឌី

សម្គាល់:

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក បានប្តូរឈ្មោះពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ វីសិនហ្វាន់ ខេមបូឌា
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆាយលីស រ៉ូយ៉ាល់ ហ្វាយនែន ភីអិលស៊ី បានប្តូរឈ្មោះពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សែលខាត ហ្វាយនែន ភីអិលស៊ី
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ណុងហឹប ហ្វាយនែន (ខេមបូឌា) ម.ក បានប្តូរឈ្មោះពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមិក ភីអិលស៊ី
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឃ្វីន ហ្វាយនែន ម.ក បានក្លាយខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឃី ភីអិលស៊ី
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាន់នី ម៉ាយក្រូហ្វាយនែន អ៊ីនស៊ីធ្យូសិន ភីអិលស៊ី បានក្លាយខ្លួនពីគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អេផល ហ្វាយនែន ភីអិលស៊ី

## ឧបសម្ព័ន្ធ ៤

## បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

List of Bank and Financial Institutions

**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

December 31, 2018

| ល.រ<br>No. | ឈ្មោះគ្រឹះស្ថាន/ក្រុមហ៊ុន<br>Name of Institutions | អាសយដ្ឋាន<br>Address | ទូរស័ព្ទទំនាក់ទំនង<br>Telephone |
|---|---|---|---|
| **១. ធនាគារពាណិជ្ជ** ( Commercial Banks ) | | | |
| 1 | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>ACLEDA Bank Plc. | #៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br># 61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh | 023 998 777 |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់<br>Advanced Bank of Asia Limited | #១៤១ ១៤៦ ១៤៨ និង ១៤៨ អាបេសេដេ និង #១៥ និង ១៥៣ អាបេសេ មហាវិថីព្រះសីហនុ ភូមិទី៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>#141, 146, 148 & 148 ABCD and #15 & 153 ABC,Preah Sihanouk Blvd., Phum4, Sangkat Boeung Keng Kang Ti Muoy, Khan ChamkarMon, Phnom Penh | 023 225 333 |
| 3 | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង)<br>Vietnam Bank for Agriculture and Rural Development Cambodia Branch | #៣៦៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br># 364, Preah Monivong Blvd, Sangkat Boeung keng kang1, Khan Chancarmon,Phnom Penh | 023 223 750 |
| 4 | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ (កម្ពុជា)<br>ANZ Royal Bank (Cambodia) Ltd. | #២0FE-EO វិថីក្រមួនស កែងផ្លូវ៦៧ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#20FE-E0, Corner of Kramoun Sar and St. 67, Sangkat Phsar Thmey 1, Khan Daun Penh, Phnom Penh | 023 999 000 |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា<br>Bangkok Bank Public Company Limited, Cambodia Branch | #៣៤៤ (ជាន់ទី១ និងទី២) មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br># 344 (1st, 2nd floor), Mao Tse Toung Boulevard, Sangkat toul Svay Prey 1, Khan Chamkar Mon, Phnom Penh | 023 224 404 |
| 6 | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី<br>Bank for Investment&Development of Cambodia Plc. | #៣៧០ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>#370, Preah Monivong Blvd., Sangkat Beong Keng Kong 1, Khan Chamkarmon, Phnom Penh | 023 210 044 |
| 7 | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ<br>Bank of China (Hong Kong) Limited Phnom Penh Branch | វិមានកាណាឌីយ៉ា (៣១៥) ជាន់ទី១-ទី២ មហាវិថីព្រះមុន្នីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>Canadia Tower (315) 1st- 2nd Floor, Preah Monivong Blvd, Sangkat Wat Phnom, Khan Don Penh,Phnom Penh | 023 988 885 |
| 8 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ<br>Bank of India Phnom Penh Branch | #៦៨(ជាន់ផ្ទាល់ដី) ក្នុងអគារ ICON មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>#68 (Eo), Building ICON, Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkamorn, Phnom Penh | 023 219 108 |
| 9 | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក<br>B.I.C (Cambodia) Bank Plc. | ផ្ទះលេខ៤៦២ ផ្លូវលេខ៩៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br># 462, Street 93, Sangkat Tonle Basak, Khan Chamkar Mon, Phnom Penh | 023 901 338 |
| 10 | ធនាគារ ប៊ូយ៉ុង ខ្មែរ<br>Booyoung Khmer Bank | #៨៦-៨៨ មហាវិថីព្រះនរោត្តម សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br># 86-88, Preah Norodom Blvd, Sangkat Chaktomuk,Khan Daun Penh,  Phnom Penh | 023 952 888 |
| 11 | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ)<br>Branch of Kasikorn Bank Public Company Limited (Phnom Penh) | ផ្ទះលេខ៤៥ មហាវិថីព្រះសីហនុ កែងផ្លូវលេខ ៥៩ ភូមិ៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#45, Preah Sihanouk Blvd, Corner of street No.59, Phum 6, Sangkat Chaktomuk, Khan Daun Penh, Phnom Penh | 077 555 366 / 023 214 998 /<br>023 214 999 |
| 12 | សាខាធនាគារ អ៊ិនដាសស្ទ្រៀល ប៊ែង អហ្វ ខូរៀ "ភ្នំពេញ"<br>Branch of Industrial Bank of Korea "Phnom Penh" | អាគារលេខ S២-២៣ ជីអូឡាំព្យា ស៊ីធី មហាវិថីព្រះមុនីរ៉េត (លេខ ២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>No S2-23 The Olympia City, Preah Monireth Blvd (No 217), Sangkat Veal Vong, Khan Prampir Meakkakra, Phnom Penh | 023 964 202/ 012 608 898<br>soungborath@ibk.co.kr |
| 13 | សាខាធនាគារ មីហ្ស៊ូហូ អិលធីឌី<br>Branch of Mizuho Bank, Ltd. | អគារភ្នំពេញថាវើរ៍ លេខ៤៤៥ ជាន់ទី១៣អេ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>Phnom Penh Tower (445), Floor 13 A, Preah Monivong Blvd, Sangkat Beoung Prolit, Khan 7 Makara, Phnom Penh | 017 222 024 / 023 964 490 |
| 14 | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី<br>BRED Bank (Cambodia) Plc. | #៣០ មហាវិថី ព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#30, Preah Norodom Blvd, Sangkat Phsar Thmey 3, Khan Daun Penh, Phnom Penh | 092 233 850 / 023 999 222 |
| 15 | ធនាគារ កម្ពុជាអាស៊ី ចំកាត់<br>Cambodia Asia Bank Ltd. | #៧៥C ០៣៦ វិថីព្រះសីហនុ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>#75C 036,  Preah Sihanouk Blvd, Sangkat Veal Vong, Khan 7makara, Phnom Penh | 023 980 000 |
| 16 | ធនាគារ មេគង្គកម្ពុជា មហាជន ទទួលខុសត្រូវមានកំរិត<br>Cambodia Mekong Bank Public Limited | #៤៤៥ មហាវិថីព្រះមុនីវង្ស  សង្កាត់ស្រះចក ខណ្ឌដូនពេញ  រាជធានីភ្នំពេញ<br># 445, Preah Monivong Blvd., Sangkat Srah Chak, Khan Daun Penh, Phnom  Penh | 023 430 980 |
| 17 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ<br>Cambodia Post Bank Plc. | # ២៦៥-២៦៩ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#265-269 Ang Duong Street, Sangkat Wat phnom,  Khan Daun Penh, Phnom Penh | 070 200 002 /<br>023 220 773- 220 772 |
| 18 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់<br>Cambodian Commercial Bank Ltd. | #២៦ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#26, Preah Monivong Blvd, Sangkat Phsar Thmey 2, Khan Daun Penh, Phnom Penh | 023 426 145 |
| 19 | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី<br>Cambodian Public Bank Plc. | #២៣ ផ្លូវ១១៤ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#23, 114 St., Sangkat Phsar Thmey 2, Khan Daun Penh,Phnom Penh | 023 222 880 / 222 881 /<br>222 881 |
| 20 | ធនាគារ កាណាឌីយ៉ា ក.អ<br>Canadia Bank Plc. | #៣១៥ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#315, Preah Ang Duong Street, Sangkat Wat Phnom, Khan Daun Penh, Phnom Penh | 023 868 222 |
| 21 | សាជីវកម្មធនាគារកាថេយូណៃធីតកម្ពុជា ចំកាត់<br>Cathay United Bank Cambodia Corp, Ltd. | #៦៨ វិថីសម្តេចប៉ាន់ (២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#68, Samdech Pan St.(214), Sangkat Boeung Raing, Khan Daun Penh, Phnom Penh | 023 211 211 / 222 438 |
| 22 | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក<br>Chief (Cambodia) Commercial Bank Plc. | ផ្ទះលេខ សេ-០១ ផ្លូវអ៊ែ ១១ កែងផ្លូវ ៧០ ភូមិ ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#C01, St. R11 corner St. 70, Phum 1, Sangkat Sras Chork, Khan Daun Penh, Phnom Penh | 023 900 878 |

| ល.រ | ឈ្មោះគ្រឹះស្ថាន/ក្រុមហ៊ុន | អាសយដ្ឋាន | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| 23 | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី<br>CIMB Bank Plc. | #២០ អាបេ មហាវិថីព្រះនរោត្តម កែងផ្លូវ ១១៨ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#20A/B, Preah Norodom Blvd, Sangkat Phsar Chas, Khan Dong Penh, Phnom Penh | 023 988 388 |
| 24 | ធនាគារ ពាណិជ្ជទី១ សាខាភ្នំពេញ<br>First Commercial Bank Phnom Penh Branch | #៦៦ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br># 66, Preah Norodom Blvd., Sangkat Chey Chumneas,Khan Daun Penh, Phnom Penh | 023 210 026 |
| 25 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា<br>Foreign Trade Bank of Cambodia | #៣៣ C-D វិថីឆេកូស្លូវ៉ាគី សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>#33 C-D, Cheque Slovakia blvd, Khan 7 Makara, Phnom Penh | 023 724 466 / 725 266 /<br>722 466 |
| 26 | ធនាគារ ហុង លីអុង(ខេមបូឌា) ភីអិលស៊ី<br>Hong Leong Bank ( Cambodia) Plc. | # ២៨ ផ្លូវ ២១៤ កែង ផ្លូវ ៥១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#28, St. 214 Corner St. 51, Sangkat Beoung Raing, Khan Daun Penh ,Phnom Penh | 023 999 711 |
| 27 | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ<br>ICBC Limited Phnom Penh Branch | អាគារ Exchange Square (ជាន់ផ្ទាល់ដី) លេខ ១៩ និង ២០ ផ្លូវលេខ ១០៦ ភូមិ ២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>Exchange Square (Ground Floor) No. 19 and 20, Street 106, Phum Pir, Sangkat Voat Phnom, Khan Doun Penh, Phnom Penh | 023 955 880 |
| 28 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី<br>Kookmin Bank Cambodia Plc. | #៥៥ ផ្លូវ ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#55, 214 St. Sangkat Boeung Raing, Khan Daun Penh, Phnom Penh | 023 999 300 |
| 29 | ធនាគារ ក្រុងថៃ ចំកាត់ (មហាជន) សាខាភ្នំពេញ<br>Krung Thai Bank Public Co., Ltd. Phnom Penh Branch | #១៤៩ ផ្លូវលេខ២១៥ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ<br># 149, 215 Road, Sangkat Phsar Depo1, Khan Toulkork,Phnom Penh | 023 882 959 |
| 30 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី<br>MAYBANK (Cambodia) Plc. | #៤៣, មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#43, Preah Norodom Blvd, Sangkat Psar Thmei3, Khan Doun Penh, Phnom Penh | 023 210 255 / 210 123 |
| 31 | ធនាគារ អ៊ឹមប៊ី ភីអិលស៊ី សាខាភ្នំពេញ កម្ពុជា<br>MB Bank Plc. Phnom Penh Branch Cambodia | #៤៣៩ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>Phnom Penh tower ( # 445), 1and 2 Floor, Preah Monivong Blvd, Sangkat Boeung Prolit, Khan 7 Makara, Phnom Penh | 023 964 666 |
| 32 | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមើសល សាខាភ្នំពេញ<br>Mega International Commercial Bank Phnom Penh Branch | #១៣៩ ផ្លូវ២៧៤ កែងផ្លូវ ៤១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>#139, St. 274&41, Sangkat Boeung Kengkang 1, Khan Chamkarmon,Phnom Penh | 023 988 101 / 218 540 |
| 33 | ធនាគារ ហ្វីលីព ភីអិលស៊ី<br>Phillip Bank Plc. | #២៧ DEF មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#27DEF, Preah Monivong Blvd, Sangkat Sraschok, Khan Daun Penh, Phnom Penh | 023 218 086 |
| 34 | ធនាគារ ភ្នំពេញ ពាណិជ្ជ<br>Phnom Penh Commercial Bank | #២១៧ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>#217, Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkamorn, Phnom Penh | 023 999 500 |
| 35 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា<br>RHB Indochina Bank Limited | #២៦៣ ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#263, Ang Duong St. Sangkat Wat Phnom,Khan Daun Penh, hnom Penh | 023 992 833 |
| 36 | ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី<br>Saigon Thuong Tin Bank (Cambodia) | #៦០ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#60, Preah Norodom Blvd, Sangkat Chey Chumnas, Khan Daun Penh, Phnom Penh | 023 223 422 |
| 37 | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី<br>Saigon-Hanoi Bank Cambodia Plc. | #១០៧ មហាវិថីនរោត្តម សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>#107, Preah Norodom Blvd, Sangkat Beoung Reang, Khan Doun Penh, Phnom Penh | 023 221 900 |
| 38 | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក<br>Shinhan Bank (Cambodia) Plc. | វ៉ាន់ដាថោវើ លេខ ៧៩ មហាវិថីកម្ពុជាក្រោម សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>Vanda Tower No 79, Kampuchea Krom Blvd, Sangkat Monourom, Khan Prampir Meakkakra, Phnom Penh | 023 727 380 |
| 39 | ធនាគារ ស្ថាបនា ភីអិលស៊ី<br>Sathapana Bank Plc. | #៨៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br># 83, Preah Norodom Blvd, Sangkat Phsar Thmei Ti Bei, Khan Daun Penh, Phnom Penh | 023 999 010 |
